# សំណួរ និង ចម្លើយ

## ភាគទី១

## សំណួរដ៏សំខាន់៥យ៉ាងស្តីអំពីដំណឹងល្អរបស់ព្រះយេស៊ូវ

## និពន្ធដោយ ៖ លោកគ្រូ ស៊ីវ៉ែត គ្រីស នៅខេត្តបាត់ដំបង

## រៀបរៀងដោយ ៖ សមាគមស្វែងរកប្រាជ្ញាព្រះគម្ពីរព្រះយេស៊ូវ

www.facebook.com/SeekingtheWisdomofJesusinKhmer

សៀវភៅនេះមិនគួរបោះពុម្ព ឬលក់ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធឡើយៗ

រាល់ការស្នើសុំសម្រាប់ការអនុញ្ញាតឲ្យបោះពុម្ព ឬថតចម្លងសៀវភៅនេះ សូមទាក់ទងអ្នកនិពន្ធ

(ជាភាសាខ្មែរ ឬជាភាសាអង់គ្លេស) តាមរយៈអ៊ីម៉ែល seekingwisdomofJesus@gmail.com

បើសិនជាលោកអ្នកមានមតិយោបល់ ឬមានចម្ងល់នៅចំណុចសំណួរណាមួយ

សូមទាក់ទងអ្នកនិពន្ធតាមរយៈអ៊ីម៉ែលខាងលើ

រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៨

# មាតិកា

សេចក្តីផ្តើម ........ 1

មេរៀនទី១ តើអ្វីជាគោលបំណងត្រឹមត្រូវក្នុងការជឿលើព្រះយេស៊ូវ ? ........ 4

មេរៀនទី២ តើព្រះយេស៊ូវបានសន្យាប្រទានអ្វីខ្លះចំពោះអ្នកដែលជឿ ហើយដើរតាមទ្រង់ ? ........ 9

មេរៀនទី៣ តើការកែប្រែចិត្តពិតប្រាកដមានន័យយ៉ាងដូចម្តេច ? ........ 21

មេរៀនទី៤ តើអ្វីជាការលះបង់ និងសេចក្តីអំណរនៃការក្លាយជាសិស្សដ៏ពិតរបស់ព្រះយេស៊ូវ ? ........ 27

មេរៀនទី៥ តើពិធីជ្រមុជទឹកមានន័យយ៉ាងដូចម្តេច ? ........ 36

ចម្លើយនៃសំណួរមេរៀនផ្សេងៗ ........ 40

# សេចក្ដីផ្ដើម

## គោលបំណងនៃសៀវភៅនេះ

គោលបំណងធំជាងគេនៃសៀវភៅនេះគឺ នាំលោកអ្នកឲ្យយល់ច្បាស់នូវអត្ថន័យនៃដំណឹងល្អរបស់ព្រះយេស៊ូវ ។ ជំនឿជឿលើព្រះយេស៊ូវ ដើម្បីទទួលបានសេចក្ដីសង្គ្រោះ គឺជាការសម្រេចចិត្តដែលមានសារៈសំខាន់បំផុត ហើយវាក៏ជាការសម្រេចចិត្តមួយដែលនាំមកនូវការផ្លាស់ប្ដូរជាច្រើននៅក្នុងជីវិតរបស់យើង ។ ដូច្នេះ ការសម្រេចចិត្តនេះ មិនមែនចេះតែធ្វើទៅ ដោយមិនបានយល់ច្បាស់ថា ខ្លួននឹងត្រូវធ្វើអ្វីបន្ទាប់ពីនោះឡើយ ។

ព្រះគម្ពីរបរិសុទ្ធបានរំឭកដាស់តឿនមនុស្សយើងម្ដងហើយម្ដងទៀតថា នៅថ្ងៃដែលព្រះជាម្ចាស់ជំនុំជម្រះមនុស្សលោក នៅថ្ងៃនោះនឹងមានមនុស្សជាច្រើនដែលមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ហើយងឿងឆ្ងល់ថា ហេតុអ្វីបានជាព្រះយេស៊ូវមិនទទួលស្គាល់ពួកគេ ហើយបោះពួកគេចោលទៅក្នុងបឹងភ្លើងអស់កល្បជានិច្ច ។ សូមអានព្រះបន្ទូលដាស់តឿនរបស់ព្រះយេស៊ូវទៅកាន់សិស្សរបស់ទ្រង់ ៖

> **មិនមែនអស់អ្នកណាដែលគ្រាន់តែនិយាយមកខ្ញុំថា ឱព្រះអម្ចាស់ៗអើយ ដែលនឹងចូលទៅក្នុងនគរស្ថានសួគ៌នោះទេ គឺជាអស់អ្នកដែលធ្វើតាមព្រះហឫទ័យនៃព្រះវរបិតា ដែលគង់នៅស្ថានសួគ៌វិញទេតើ ។ នៅថ្ងៃនោះ នឹងមានមនុស្សជាច្រើននិយាយមកខ្ញុំថា ឱព្រះអម្ចាស់ៗអើយ តើយើងខ្ញុំមិនបានទាយដោយនូវព្រះនាមទ្រង់ ហើយដេញអារក្សដោយនូវព្រះនាមទ្រង់ ព្រមទាំងធ្វើការឫទ្ធិបារមីជាច្រើន ដោយនូវព្រះនាមទ្រង់ទេឬអី ។ នោះខ្ញុំនឹងនិយាយដោយត្រង់ថា អញមិនដែលបានស្គាល់ឯងរាល់គ្នាទេ នែ ពួកទទឹងច្បាប់អើយ ចូរថយចេញពីអញទៅ ។** (*ម៉ាថាយ ៧:២១-២៣*)

សព្វថ្ងៃនេះ នៅស្រុកខ្មែរមានមនុស្សជាច្រើនដែលស្មានថា ខ្លួនបានជឿលើព្រះយេស៊ូវហើយ ប៉ុន្តែពួកគេមិនមែនជាកូនរបស់ព្រះដ៏ពិតនោះទេ ។ អ្នកខ្លះបញ្ឆោតខ្លួនឯងដោយចាត់ទុកថា ខ្លួនជាអ្នកជឿដោយសារធ្លាប់ចូលរួមថ្វាយបង្គំព្រះយេស៊ូវជាមួយក្រុមជំនុំមួយ ហើយអ្នកខ្លះនិយាយថា «ខ្ញុំបានថ្វាយខ្លួនទទួលពិធីជ្រមុជទឹកហើយ» ។ អ្នកផ្សេងទៀតស្មានថា ខ្លួនឯងក្លាយជាគ្រីស្ទបរិស័ទហើយ ពីព្រោះពួកគេលែងថ្វាយបង្គំរូបព្រះ ឈប់សែន ហើយលែងអុជធូបថ្វាយព្រះដទៃ ។ អ្នកខ្លះទៀតធ្លាប់ចុះទៅផ្សព្វផ្សាយ

ដំណឹងល្អ បានថ្វាយតង្វាយដល់ទ្រង់ ហើយមានអ្នកខ្លះក៏បានជួយបង្រៀនព្រះគម្ពីរដល់សិស្សថែមទៀតផង ប៉ុន្តែពួកគេនៅតែមិនទាន់ក្លាយជាកូនរបស់ព្រះដ៏ពិតនៅឡើយទេ ។ ពួកគេគិតថា ខ្លួនជាកូនរបស់ព្រះ ដោយសារគេបានប្រព្រឹត្តទាំងអស់នោះ ប៉ុន្តែនៅពេលដែលថ្ងៃជំនុំជម្រះនៃព្រះជាម្ចាស់មកដល់ ពួកគេនឹងត្រូវបានភ្ញាក់ផ្អើលថា គេមិនបានរួចពីទោសនៃអំពើបាបរបស់ខ្លួនទេ ហើយក៏មិនមានសេចក្ដីសង្គ្រោះពីព្រះយេស៊ូវដែរ ។

អ្នកនិពន្ធសៀវភៅនេះសង្ឃឹមថា អស់លោកអ្នកដែលអាន និងសិក្សាសៀវភៅនេះនឹងពិចារណា ហើយល្បងខ្លួនមើលថា តើខ្ញុំស្ថិតនៅក្នុងជំនឿពិតប្រាកដឬទេ ? តើខ្ញុំបានកែប្រែចិត្តពិតប្រាកដឬទេ ? ដើម្បីជួយយើងក្នុងការសិក្សាព្រះគម្ពីរអំពីអត្ថន័យនៃដំណឹងល្អរបស់ព្រះយេស៊ូវ យើងនឹងលើកឡើងនូវបទគម្ពីរមួយពីប្រវត្តិសាស្ត្រក្រុមជំនុំនៅសម័យដើម ។

# ទីបន្ទាល់របស់សាវកប៉ុលក្នុងកិច្ចការ ២៦:១៦-២១

សាវកប៉ុលគឺជាអ្នកផ្សព្វផ្សាយដំណឹងល្អ លោកមានបេសកកម្មសំខាន់មួយគឺ នាំមនុស្សនៅគ្រប់ស្រុកឲ្យជឿលើព្រះយេស៊ូវ ។ មុនពេលគាត់ជឿលើព្រះយេស៊ូវ គាត់ជាអ្នកដឹកនាំសាសនាម្នាក់ឈ្មោះសុល ដែលមានចិត្តខ្នះខ្នែងចំពោះសាសនារបស់គាត់ ។ គាត់ស្អប់អ្នកជឿលើព្រះយេស៊ូវ ហើយវាយដំពួកគេ ព្រមទាំងចាប់ដាក់គុកពួកគេខ្លះទៀតផង ។ ថ្ងៃមួយ នៅពេលដែលគាត់កំពុងតែធ្វើដំណើរទៅកាន់ទីក្រុងមួយ ដើម្បីបៀតបៀនអ្នកជឿលើព្រះយេស៊ូវនៅទីនោះ ព្រះអង្គបានបើកសម្ដែងអង្គទ្រង់ឲ្យគាត់បានឃើញ ។ នៅពេលនោះ សុលបានសម្រេចចិត្តទទួលជឿលើព្រះយេស៊ូវ ។ ព្រះយេស៊ូវបានប្រាប់សុលឲ្យប្រកាសដំណឹងល្អទៅដល់ជាតិសាសន៍ទាំងឡាយ ហើយថា គាត់នឹងមានការឈឺចាប់ជាច្រើនដោយសារតែដំណឹងល្អនេះ ។ បន្ទាប់ពីព្រឹត្តិការណ៍នោះ សុលបានទទួលឈ្មោះថ្មីគឺ «ប៉ុល» ។ (បើសិនជាលោកអ្នកចង់អានអំពីទីបន្ទាល់របស់សាវកប៉ុលថែមទៀត នោះសូមអានកិច្ចការ ៩:១-៣១) ។

ព្រះគម្ពីរកិច្ចការ ២៦ បង្រៀនយើងអំពីប្រវត្តិនៃបេសកកម្មរបស់លោកប៉ុលថែមទៀត ។ នៅពេលនោះ លោកប៉ុលមានវ័យចាស់ហើយ ។ លោកបានផ្សាយដំណឹងល្អ ហើយនាំមនុស្សជាច្រើនឲ្យទទួលជឿលើព្រះយេស៊ូវនៅតាមស្រុកផ្សេងៗ ។ លោកប៉ុលត្រូវបានអ្នកដឹកនាំសាសនានៅក្រុងយេរូសាឡឹមចាប់ខ្លួនលោក ហើយរកឱកាសសម្លាប់គាត់ចោលថែមទៀតផង ។ អ្នកដឹកនាំសាសនាបាននាំលោកប៉ុលទៅគាល់ស្ដេចនៅសម័យនោះ ពីព្រោះពួកគេសង្ឃឹមថា ស្ដេចនឹងប្រកាសដាក់ទោសដល់លោកប៉ុល ។ ពេលនោះលោកត្រូវធ្វើទីបន្ទាល់ឲ្យស្ដេចស្ដាប់ ។ នៅក្នុងទីបន្ទាល់នោះ លោកប៉ុលបានប្រាប់ស្ដេចយ៉ាងច្បាស់អំពីរបៀបដែលព្រះយេស៊ូវបានបង្គាប់ឲ្យលោកបំពេញបេសកកម្មជាអ្នកផ្សាយដំណឹងល្អ ហើយអំពីមូលហេតុផ្សេងៗដែលអ្នកដឹកនាំសាសនាព្យាយាមសម្លាប់គាត់ចោល ។

ចូរក្រោកឈរឡើង ដ្បិតខ្ញុំបានលេចមកឲ្យអ្នកឃើញ ដើម្បីនឹងតាំងអ្នកឲ្យធ្វើជាអ្នកបំរើ ហើយជាទីបន្ទាល់ពីអស់ទាំងការដែលអ្នកបានឃើញហើយ ព្រមទាំងការដែលខ្ញុំនឹងលេចមកឲ្យអ្នកឃើញទៅមុខទៀត ។ ខ្ញុំបានញែកអ្នកចេញពីបណ្ដាជន និងពីពួកសាសន៍ដទៃ ដើម្បីនឹងចាត់អ្នកឲ្យទៅឯគេវិញ ប្រយោជន៍នឹងបំភ្លឺភ្នែកគេ ឲ្យបានបែរចេញពីសេចក្ដីងងឹតមកឯពន្លឺ ហើយពីអំណាចអារក្សសាតាំង មកឯព្រះវិញ ដើម្បីឲ្យគេបានរួចពីបាប ហើយបានទទួលមរតកជាមួយនឹងពួកអ្នកដែលបានញែកជាបរិសុទ្ធ ដោយសារសេចក្ដីជំនឿជឿដល់ខ្ញុំ ។ ដូច្នេះ បពិត្រព្រះរាជាអ័គ្រីប៉ាអើយ ទូលបង្គំមិនបានចចេសនឹងការជាក់ស្ដែងពីស្ថានសួគ៌នោះទេ គឺទូលបង្គំបានប្រាប់ឲ្យមនុស្សទាំងអស់ប្រែចិត្ត ហើយងាកបែរមកឯព្រះវិញ ទាំងប្រព្រឹត្តបែបសំណាំនឹងការប្រែចិត្តផង គឺប្រាប់ដល់ពួកអ្នកដែលនៅក្រុងដាម៉ាសជាមុនដំបូង រួចនៅក្រុងយេរូសាឡឹម នឹងគ្រប់ក្នុងខេត្តយូដា ហើយដល់អស់ទាំងសាសន៍ដទៃផង ។ ដោយហេតុនោះបានជាពួកសាសន៍យូដាចាប់ទូលបង្គំនៅក្នុងព្រះវិហារ ហើយព្យាយាមនឹងសម្លាប់ទូលបង្គំចោល ។ (*កិច្ចការ ២៦:១៦-២១*)

ដើម្បីជួយយើងឲ្យយល់ពីអត្ថន័យនៃដំណឹងល្អរបស់ព្រះយេស៊ូវកាន់តែស៊ីជម្រៅ សៀវភៅនេះមានបំណងឆ្លើយសំណួរ៥ ដែលមានសារៈសំខាន់សម្រាប់យើងគ្រប់ៗគ្នា ជាពិសេសអ្នកដែលមិនទាន់យល់ច្បាស់អំពីដំណឹងល្អ ឬអ្នកដែលទើបនឹងជឿលើព្រះយេស៊ូវថ្មី ។ នៅពេលដែលយើងសិក្សាសំណួរនីមួយៗ យើងនឹងយកបទគម្ពីរកិច្ចការ ២៦:១៦-២១ ជាគោល ។ នៅក្នុងសៀវភៅនេះ យើងនឹងព្យាយាមឆ្លើយសំណួរដូចខាងក្រោម ៖

១. តើអ្វីជាគោលបំណងត្រឹមត្រូវក្នុងការជឿលើព្រះយេស៊ូវ ?
២. តើព្រះយេស៊ូវបានសន្យាប្រទានអ្វីខ្លះចំពោះអ្នកដែលជឿ ហើយដើរតាមទ្រង់ ?
៣. តើការកែប្រែចិត្តពិតប្រាកដមានន័យយ៉ាងដូចម្ដេច ?
៤. តើអ្វីជាការលះបង់ និងសេចក្ដីអំណរនៃការក្លាយជាសិស្សដ៏ពិតរបស់ព្រះយេស៊ូវ ?
៥. តើពិធីជ្រមុជទឹកមានន័យយ៉ាងដូចម្ដេច ?

សូមព្រះជាម្ចាស់ប្រទានពរដល់អស់លោកអ្នកដែលអាន និងគិតពិចារណាលើសៀវភៅនេះ ។

# មេរៀនទី១

# តើអ្វីជាគោលបំណងត្រឹមត្រូវក្នុងការជឿលើព្រះយេស៊ូវ ?

នៅគ្រប់ប្រទេសលើពិភពលោកទាំងមូល មានមនុស្សមួយចំនួនបានអះអាងថា ខ្លួនជឿលើព្រះយេស៊ូវ ។ ក្នុងបណ្ដាអស់លោកអ្នកដែលបានអះអាងថា ខ្លួនជឿលើព្រះយេស៊ូវ មានពីរប្រភេទគឺ ៖

១. អ្នកដែលជឿលើព្រះយេស៊ូវតាមគោលបំណងមិនត្រឹមត្រូវ

២. អ្នកដែលជឿលើព្រះយេស៊ូវតាមគោលបំណងត្រឹមត្រូវ

នៅក្នុងប្រទេសកម្ពុជាក៏មានមនុស្សដូចជាប្រភេទទាំងពីរនេះផងដែរ ។ មុនពេលយើងគិតពិចារណាលើគោលបំណងត្រឹមត្រូវក្នុងការជឿលើព្រះយេស៊ូវ យើងត្រូវគិតអំពីគោលបំណងមិនត្រឹមត្រូវជាមុនសិន ។

## គោលបំណងមិនត្រឹមត្រូវក្នុងការជឿលើព្រះយេស៊ូវ ៖

ក្នុងរយៈពេល២៥ឆ្នាំកន្លងមកហើយ នៅក្នុងប្រទេសកម្ពុជាមានក្រុមគ្រីស្ទានជាច្រើន (អង្គការ និកាយ និងជនបរទេស) បានចូលមកស្រុកខ្មែរ ដើម្បីផ្សព្វផ្សាយដំណឹងល្អរបស់ព្រះយេស៊ូវ ហើយក្រុមខ្លះក៏មានបំណងជួយបង្កើតក្រុមជំនុំក្នុងតំបន់ផ្សេងៗផងដែរ ។ ពួកគេភាគច្រើនមានចិត្តល្អ ហើយមានចិត្តស្មោះត្រង់ចង់ផ្គាប់ព្រះហឫទ័យព្រះអង្គ ប៉ុន្ដែមានអង្គការ និកាយ ឬជនបរទេស និងអ្នកដឹកនាំក្រុមជំនុំនៅក្នុងស្រុកខ្មែរមួយចំនួនធំបានប្រើវិធីសាស្ត្រ ឬមធ្យោបាយផ្សេងៗ ដែលបណ្ដាលឲ្យជនជាតិខ្មែរជាច្រើនអះអាងថា ខ្លួនជឿលើព្រះយេស៊ូវតាមគោលបំណងមិនត្រឹមត្រូវ ។ គោលបំណងមិនត្រឹមត្រូវមួយចំនួនបានរៀបរាប់ខាងក្រោមនេះ ៖

**១. មនុស្សខ្លះអះអាងថា ខ្លួនជឿលើព្រះយេស៊ូវ ដើម្បីទទួលផលប្រយោជន៍ខាងសម្ភារៈ**

<u>**ឧទាហរណ៍**</u> **៖**

- ពួកគេអាចទទួលសម្ភារៈពីអង្គការបរទេស ដែលចែកអំណោយដូចជាអង្ករ ជ្រូកយកទៅចិញ្ចឹម អណ្ដូងទឹក ឬថ្នាំពេទ្យ ។ ល ។
- ពួកគេអាចទទួលប្រាក់ខែ ឬការងារនៅក្នុងអង្គការណាមួយ

**២. មនុស្សខ្លះអះអាងថា ខ្លួនជឿលើព្រះយេស៊ូវ ដើម្បីទទួលផលប្រយោជន៍ខាងចំណេះដឹង**

<u>ឧទាហរណ៍</u> ៖

- ពួកគេអាចរៀនភាសាអង់គ្លេស ឬភាសាកូរ៉េ ដោយឥតគិតថ្លៃ ។ ល ។
- ពួកគេអាចរៀនកុំព្យូទ័រ ឬជំនាញផ្សេងៗ ឬមានឱកាសចូលលេងក្នុងក្រុមបាល់ទាត់ណាមួយ
- ពួកគេអាចសិក្សានៅសាលាក្រៅប្រទេស

**៣. មនុស្សខ្លះអះអាងថា ខ្លួនជឿលើព្រះយេស៊ូវ ព្រោះពួកគេគិតថា ជំនឿជឿលើព្រះយេស៊ូវមានអំណាច (ឬបារមី) ខ្លាំងជាងផ្លូវសាសនាចាស់របស់ខ្លួន**

<u>ឧទាហរណ៍</u> ៖

- អ្នកខ្លះមើលឃើញថា ប្រទេសមួយចំនួនដែលមានអ្នកជឿលើព្រះយេស៊ូវច្រើន គឺជាប្រទេសអ្នកមាន ។ ដូច្នេះហើយពួកគេសង្ឃឹមថា ការជឿលើព្រះយេស៊ូវនឹងធ្វើឲ្យជីវភាព និងប្រទេសពួកគេកាន់តែប្រសើរឡើងមួយកម្រិតទៀត ។
- អ្នកខ្លះគិតថា ដោយសារព្រះយេស៊ូវមានអំណាច (បារមី) ខ្ពស់ជាងព្រះ និងវិញ្ញាណផ្សេងៗរបស់ពួកគេ ទ្រង់អាចប្រោសជំងឺរបស់ពួកគេ ហើយជួយពួកគេឲ្យមានសុខភាពល្អថែមទៀតផង ។

**៤. មនុស្សខ្លះអះអាងថា ខ្លួនជឿលើព្រះយេស៊ូវ ព្រោះពួកគេគិតថា ជំនឿជឿលើព្រះយេស៊ូវសប្បាយជាងផ្លូវសាសនាចាស់របស់ខ្លួន**

<u>ឧទាហរណ៍</u> ៖

- អ្នកខ្លះមើលឃើញថា នៅក្នុងក្រុមជំនុំព្រះយេស៊ូវមានអ្នកជឿជាច្រើនមានចិត្តសប្បុរស និងចិត្តល្អស្លូតបូត ហើយពួកគេមានបំណងចូលរួមក្នុងសហគមន៍នោះដោយសារហេតុផលទាំងអស់នេះ ។
- អ្នកខ្លះគិតថា ក្នុងកម្មវិធីថ្វាយបង្គំព្រះរៀងរាល់សប្ដាហ៍ គេមានឱកាសច្រៀងបទចម្រៀងសប្បាយ លេងឧបករណ៍ភ្លេងផ្សេងៗ ហើយអាចមានភាពសប្បាយរីករាយជាមួយនឹងមិត្តភក្តិរបស់គេ ។

**៥. មនុស្សខ្លះអះអាងថា ខ្លួនជឿលើព្រះយេស៊ូវ ព្រោះពួកគេគិតថា ជំនឿជឿលើព្រះយេស៊ូវងាយស្រួលជាងផ្លូវសាសនាចាស់របស់ខ្លួន**

<u>ឧទាហរណ៍</u> ៖

- អ្នកខ្លះគិតថា ដោយសារជំនឿជឿលើព្រះយេស៊ូវពុំមានពិធីបុណ្យផ្សេងៗដូចផ្លូវសាសនាចាស់របស់គេ ដូចនេះវាងាយស្រួលជាង ហើយក៏អាចជួយពួកគេក្នុងការសន្សំលុយកាក់ និងពេលវេលាផងដែរ ។ (សូមមើលមេរៀនទី៤ក្នុងសៀវភៅនេះអំពីការលះបង់នៃការក្លាយជាសិស្សដ៏ពិតរបស់ព្រះយេស៊ូវ ។ មេរៀននោះនឹងបង្រៀនច្បាស់លាស់ថា ជំនឿជឿលើព្រះយេស៊ូវពិតជាមានអំណរមែន តែមិនស្រួលទេ)

**៦. មនុស្សខ្លះអះអាងថា ខ្លួនជឿលើព្រះយេស៊ូវ ព្រោះជំនឿជឿលើព្រះយេស៊ូវជាជំនឿរបស់ដូនតារបស់ខ្លួន**

**ឧទាហរណ៍ ៖**

- អ្នកខ្លះគិតថា ដោយសារពួកគេបានកើតមកក្នុងគ្រួសារមួយដែលមានឪពុកម្ដាយ ឬបងប្អូនជាអ្នកជឿលើព្រះយេស៊ូវ ហេតុដូច្នេះហើយបានជាពួកគេចាត់ទុកខ្លួនឯងថាជាពួកគ្រីស្ទាន ទោះបីជាគេមិនបានកែប្រែចិត្តពិតប្រាកដ ហើយគ្មានភស្តុតាងណាដែលបង្ហាញថា ខ្លួនបានកើតជាថ្មីក៏ដោយ ។

តើការមានចិត្តចង់បានការងារធ្វើដ៏ល្អមួយ ឬចង់រៀនភាសាបរទេសនោះ ខុសឆ្គងដែរឬទេ ? អត់ទេ ! **ប៉ុន្តែ**ការទាំងអស់នោះមិនមែនជាគោលបំណងត្រឹមត្រូវក្នុងការជឿលើព្រះយេស៊ូវនោះឡើយ ។ ការលោភលន់ចង់បានផលប្រយោជន៍ជាសម្ភារៈ ឬចំណេះដឹង គឺជាអំពើបាបមួយដែលបានធ្វើឲ្យមនុស្សជាច្រើនក្នុងពិភពលោកបាត់បង់ ឬមិនបានទទួលសេចក្ដីសន្យាដ៏អស្ចារ្យរបស់ព្រះយេស៊ូវ (សូមមើលមេរៀនទី២អំពីសេចក្ដីសន្យាដ៏អស្ចារ្យទាំង២) ។

តើការមានចិត្តចង់ចូលរួមក្នុងសហគមន៍គ្រីស្ទានដោយសារហេតុផលទាំងអស់ ដែលយើងបានរៀបរាប់ខាងលើ ខុសឆ្គងដែរឬទេ ? អត់ទេ ! **ប៉ុន្តែ**ការទាំងអស់នេះនៅតែមិនមែនជាគោលបំណងត្រឹមត្រូវដែលនាំឲ្យមនុស្សយើងត្រូវតែជឿលើព្រះយេស៊ូវនោះទេ ។ បើសិនជាមនុស្សម្នាក់គិតថា ខ្លួនជឿលើព្រះគ្រីស្ទដោយសារហេតុផលទាំងនេះ នោះបង្ហាញឲ្យឃើញថា ពួកគេមិនទាន់យល់ដំណឹងល្អរបស់ព្រះយេស៊ូវនៅឡើយទេ ។ គ្មាននរណាម្នាក់ដែលជឿលើព្រះយេស៊ូវដោយសារគោលបំណងទាំងអស់នេះ បានក្លាយជាពួកគ្រីស្ទានពិតប្រាកដនោះឡើយ ។

ដោយសារគោលបំណងទាំង៦ ដែលយើងបានរៀបរាប់ខាងលើមិនមែនជាគោលបំណងត្រឹមត្រូវនោះទេ ដូច្នេះ យើងគួរតែសួរថា តើអ្វីជាគោលបំណងត្រឹមត្រូវក្នុងការជឿលើព្រះយេស៊ូវ ? ហេតុអ្វីបានជាមនុស្សទាំងអស់នៅលើផែនដីនេះត្រូវតែជឿលើព្រះយេស៊ូវ (ទាំងចាស់ទាំងក្មេង ទាំងប្រុសទាំងស្រី ទាំងអ្នកមានទាំងអ្នកក្រ ទាំងជនជាតិខ្មែរ ចាម អាមេរិកាំង កូរ៉េ ។ ល ។) ?

## គោលបំណងត្រឹមត្រូវក្នុងការជឿលើព្រះយេស៊ូវ ៖

ចម្លើយនៃសំណួរសំខាន់នេះ ៖ **មនុស្សទាំងអស់នៅលើផែនដីត្រូវតែជឿលើព្រះយេស៊ូវ ពីព្រោះមនុស្សគ្រប់គ្នាបានដាច់ចេញពីព្រះអាទិកររបស់ខ្លួន (ព្រះដែលបានបង្កើតអ្វីៗទាំងអស់) ដោយសារអំពើបាបនៅក្នុងខ្លួនពួកគេ ហើយពួកគេត្រូវផ្សះផ្សាជាមួយនឹងព្រះជាម្ចាស់វិញ ។ បើសិនជាមនុស្សយើងមិនបានផ្សះផ្សាជាមួយនឹងព្រះអាទិកររបស់ខ្លួន នោះមនុស្សយើងត្រូវទទួលទណ្ឌកម្មនៅឋាននរកអស់កល្បជានិច្ច ។**

មុនពេលយើងរៀនអំពីបញ្ហាធំជាងគេរបស់មនុស្សយើង គឺអំពើបាបនៅក្នុងចិត្តរបស់មនុស្ស (សូមមើលមេរៀនទី២) យើងគួរតែគិតពិចារណាលើរូបភាពសំខាន់ៗពីរ ដែលព្រះយេស៊ូវបានផ្ដល់ឲ្យសាវកប៉ុលកាលទ្រង់បានប្រាប់លោកអំពីបេសកកម្មរបស់លោកនៅក្នុងព្រះគម្ពីរកិច្ចការ ២៦:១៦-១៨ ។ រូបភាពទាំងពីរនេះសម្ដែងយ៉ាងច្បាស់អំពីស្ថានភាពដ៏ពិតរបស់មនុស្សយើង មុនពេលយើងបានទទួលសេចក្ដីសង្គ្រោះពីព្រះយេស៊ូវ ។

> ចូរក្រោកឈរឡើង ដ្បិតខ្ញុំបានលេចមកឲ្យអ្នកឃើញ ដើម្បីនឹងតាំងអ្នកឲ្យធ្វើជាអ្នកបំរើ ហើយជាទីបន្ទាល់ពីអស់ទាំងការដែលអ្នកបានឃើញហើយ ព្រមទាំងការដែលខ្ញុំនឹងលេចមកឲ្យអ្នកឃើញទៅមុខទៀត ។ ខ្ញុំបានញែកអ្នកចេញពីបណ្ដាជន និងពីពួកសាសន៍ដទៃ ដើម្បីនឹងចាត់អ្នកឲ្យទៅឯគេវិញ ប្រយោជន៍នឹងបំភ្លឺភ្នែកគេ ឲ្យបានបែរចេញពីសេចក្ដីងងឹតមកឯពន្លឺ ហើយពីអំណាចអារក្សសាតាំង មកឯព្រះវិញ ដើម្បីឲ្យគេបានរួចពីបាប ហើយបានទទួលមរតកជាមួយនឹងពួកអ្នកដែលបានញែកចេញជាបរិសុទ្ធ ដោយសារសេចក្ដីជំនឿជឿដល់ខ្ញុំ ។ (*កិច្ចការ ២៦:១៦-១៨*)

**រូបភាពទី១ ៖ មនុស្សយើងជា*អ្នកខ្វាក់*ខាងវិញ្ញាណ ហើយត្រូវបែរចេញពីភាពងងឹត មកឯពន្លឺវិញ**

ព្រះគម្ពីរបានបង្រៀនថា អ្នកដែលមិនទាន់ជឿលើព្រះយេស៊ូវកំពុងតែដើរក្នុងផ្លូវងងឹតខាងវិញ្ញាណ ៖

> បើសិនណាជាដំណឹងល្អរបស់យើងខ្ញុំត្រូវគ្របបាំង នោះគឺត្រូវគ្របបាំងចំពោះតែពួកអ្នកដែលកំពុងវិនាសទេ ជាពួកអ្នកដែលព្រះរបស់លោកិយនេះបានបង្អាប់ដល់គំនិតពួកគេដែលមិនជឿ ក្រែងរស្មីពន្លឺនៃដំណឹងល្អ ដែលសម្ដែងពីសិរីល្អនៃព្រះគ្រីស្ទដ៏ជារូបអង្គព្រះបានភ្លឺមកដល់គេ ។ (*២កូរិនថូស ៤:៣-៤*)

**រូបភាពទី២ ៖ មនុស្សយើងជា*ទាសករ*ខាងវិញ្ញាណ ហើយត្រូវបែរចេញពីអំណាចអារក្សសាតាំង មកឯព្រះវិញ**

ព្រះគម្ពីរបានបង្រៀនថា អ្នកដែលមិនទាន់ជឿលើព្រះយេស៊ូវកំពុងតែស្ថិតនៅក្រោមអំណាច និងការត្រួតត្រារបស់អារក្សសាតាំង ។ សាតាំងគឺជាមេអារក្ស ហើយជាខ្មាំងសត្រូវធំជាងគេរបស់ព្រះ ។ វាស្អប់ព្រះ និងអ្វីៗទាំងអស់ដែលព្រះស្រឡាញ់ ជាពិសេសមនុស្សយើង ។

> ហើយគេនឹងភ្ញាក់ដឹងខ្លួនឡើង ចេញផុតពីអន្ទាក់របស់អារក្ស ដែលវាបានចាប់គេប្រើតាមចិត្តនោះ ។ (*២ធីម៉ូថេ ២:២៦*)

**មនុស្សយើងត្រូវតែទទួលស្គាល់ថា យើងមានភាពខ្សោយ ដូចនេះមានតែព្រះយេស៊ូវប៉ុណ្ណោះ ដែលអាចបំភ្លឺភ្នែករបស់យើង និងជួយរំដោះយើងឲ្យរួចផុតពីអំណាចរបស់អារក្សសាតាំងបាន ។** ព្រះយេស៊ូវជាព្រះដែលបានបង្កើតអ្វីៗទាំងអស់ ទ្រង់បានបង្គាប់យើងគ្រប់ៗគ្នាឲ្យកែប្រែចិត្តពី (១) ការមិនដឹងគុណរបស់យើងចំពោះព្រះអង្គ (២) ការបះបោររបស់យើងដែលប្រឆាំងនឹងបញ្ញត្តិព្រះអង្គ ហើយនិង (៣) ការអាត្មានិយមរបស់យើង ដែលមិនចេះស្រឡាញ់ព្រះឲ្យអស់ពីចិត្ត ហើយក៏មិនចេះស្រឡាញ់អ្នកដទៃដូចជាខ្លួនឯង ។ យើងត្រូវតែបន្ទាបខ្លួន កែប្រែចិត្តពីអំពើបាបរបស់ខ្លួន ហើយទុកចិត្តជឿលើព្រះយេស៊ូវទាំងស្រុង ។

អរព្រះគុណព្រះអង្គ ដែលមនុស្សយើងអាចបានសង្គ្រោះពីអំណាចនៃសេចក្ដីងងឹត និងពីអំណាចរបស់អារក្សសាតាំង ! នេះជាមូលហេតុ ដែលព្រះគម្ពីរហៅការពិតទាំងអស់នេះថា ជា «ដំណឹងល្អ» !

> **ទ្រង់បានប្រោសឲ្យយើងរួចពីអំណាចនៃសេចក្ដីងងឹត ហើយផ្លាស់យើងមកក្នុងនគររបស់ព្រះរាជបុត្រាស្ងួនភ្ងានៃទ្រង់ ។** (*កូឡុស ១:១៣*)

## សំណួរមេរៀនទី១ ៖

១. យោងតាមមេរៀននេះ តើមានគោលបំណងមិនត្រឹមត្រូវអ្វីខ្លះ ដែលនាំឲ្យមនុស្សខ្លះអះអាងថា ខ្លួនបានជឿលើព្រះយេស៊ូវ ? (តម្រុយ ៖ មាន៦យ៉ាង)

២. តើអ្វីជាគោលបំណងត្រឹមត្រូវក្នុងការជឿលើព្រះយេស៊ូវ ?

៣. យោងតាមព្រះគម្ពីរកិច្ចការ ២៦:១៦-១៨ តើមានរូបភាពអ្វីខ្លះដែលសម្ដែងយ៉ាងច្បាស់លាស់អំពីស្ថានភាពរបស់មនុស្សយើងចំពោះព្រះជាម្ចាស់ ? (តម្រុយ ៖ មាន២យ៉ាង)

៤. មុនពេលមនុស្សម្នាក់ជឿលើព្រះយេស៊ូវ តើអ្នកនោះស្ថិតនៅក្រោមអំណាច និងការត្រួតត្រារបស់អ្នកណា ?

៥. តើមនុស្សយើងអាចបានសង្គ្រោះពីអំណាចនៃសេចក្ដីងងឹតខាងវិញ្ញាណ និងពីអំណាចអារក្សសាតាំងបានដែរឬទេ ?

# មេរៀនទី២

## សំណួរទី២ ៖ តើព្រះយេស៊ូវបានសន្យាប្រទានអ្វីខ្លះ ចំពោះអ្នកដែលជឿ ហើយដើរតាមទ្រង់ ?

(*សម្គាល់សម្រាប់គ្រូបង្រៀន ៖ ដោយសារមេរៀនទី២នេះវែង លោកអ្នកអាចចែកជាពីរមេរៀនក៏បានដែរ*)

នេះគឺជាសំណួរមួយដែលមនុស្សភាគច្រើនតែងតែសួរទៅកាន់អ្នកជឿលើព្រះយេស៊ូវ ។ នៅក្នុងប្រទេសកម្ពុជាក៏មានមូលហេតុជាច្រើន ដែលនាំឲ្យមនុស្សសួរសំណួរនេះផងដែរ ។ អ្នកខ្លះសួរសំណួរនេះព្រោះគាត់ចង់រកផលប្រយោជន៍ខាងសម្ភារៈ ឬផលប្រយោជន៍ខាងចំណេះដឹង ដូចជាមេរៀនទី១នៅក្នុងសៀវភៅនេះបានរៀបរាប់រួចហើយ ។ ប៉ុន្តែមានអ្នកខ្លះទៀតពិតជាស្វែងយល់ពីសេចក្ដីពិតខាងវិញ្ញាណយ៉ាងពិតប្រាកដ ។

តើព្រះយេស៊ូវបានសន្យាអ្វីខ្លះចំពោះអ្នកដែលកែប្រែចិត្ត ហើយជឿលើទ្រង់ ? មានការសន្យាជាច្រើនដែលព្រះអង្គបានប្រទានដល់អ្នកដែលទុកចិត្តជឿលើទ្រង់យ៉ាងពិតប្រាកដ ។ យើងនឹងគិតពិចារណាលើការសន្យាដ៏អស្ចារ្យតែពីរប៉ុណ្ណោះ ។ ការសន្យាទាំងពីរនេះមានចែងទុកក្នុងព្រះបន្ទូលរបស់ព្រះយេស៊ូវទៅកាន់លោកប៉ុលនៅព្រះគម្ពីរកិច្ចការ ២៦:១៨ ។

> ប្រយោជន៍នឹងបំភ្លឺភ្នែកគេ ឲ្យបានបែរចេញពីសេចក្ដីងងឹត មកឯពន្លឺ ហើយពីអំណាចអារក្សសាតាំង មកឯព្រះវិញ ដើម្បីឲ្យគេបានរួចពីបាប ហើយបានទទួលមរតកជាមួយនឹងពួកអ្នកដែលបានញែកជាបរិសុទ្ធ ដោយសារសេចក្ដីជំនឿជឿដល់ខ្ញុំ ។ (*កិច្ចការ ២៦:១៨*)

### សេចក្ដីសន្យាទី១ ៖ ព្រះយេស៊ូវនឹងអត់ទោសអំពើបាបឲ្យយើង

ព្រះជាម្ចាស់បានសន្យាថា ទ្រង់នឹងប្រោសយើងឲ្យរួចផុតពីជំងឺដ៏ធ្ងន់ធ្ងរ គឺជាជំងឺនៃអំពើបាបនៅក្នុងចិត្តរបស់យើង ដែលធ្វើឲ្យយើងស្លាប់ ហើយនិងដាច់ចេញពីព្រះ ។ នេះគឺជាការសន្យាមួយដ៏អស្ចារ្យជាងគេបំផុត !

## ១. ហេតុអ្វីបានជាយើងត្រូវការរួចពីបាប ?

យើងទាំងអស់គ្នាបានប្រព្រឹត្តអំពើបាបជាច្រើនប្រឆាំងនឹងព្រះដែលបានបង្កើតយើងមក ។ មានសារៈសំខាន់ណាស់ដែលយើងយល់ច្បាស់ថា គ្រប់អំពើបាបទាំងអស់ប្រឆាំងនឹងព្រះ មិនមែនជាអ្វីដែលប៉ះពាល់នឹងព្រេងវាសនា សំណាង ឬក៏ជាតិក្រោយរបស់មនុស្សយើងនោះឡើយ ។ មុនពេលដែលយើងអាចយល់ពីមូលហេតុដែលយើងត្រូវការរួចពីបាបនោះ គឺយើងត្រូវតែយល់អត្ថន័យនៃអំពើបាបយ៉ាងស៊ីជម្រៅជាមុនសិន ។ តើព្រះគម្ពីរបានពិពណ៌នានិស្ស័យ និងលក្ខណៈនៃអំពើបាបយ៉ាងដូចម្តេច ? យើងពិពណ៌នានូវអំពើបាបយ៉ាងតិច៣យ៉ាង ៖

១. អំពើបាបគឺជាការមិនគោរពព្រះជាម្ចាស់ឲ្យសមនឹងឋានៈព្រះអង្គ ។

២. អំពើបាបគឺជាការមិនស្តាប់បង្គាប់ព្រះជាម្ចាស់ ។

៣. អំពើបាបគឺជាការមានចិត្តអាត្មានិយម និងអំនួតចំពោះព្រះ និងអ្នកដទៃ ។

ដូច្នេះ ហេតុអ្វីយើងត្រូវការរួចពីបាប ?

ក. យើងត្រូវការរួចពីបាប ពីព្រោះយើងមិនបានគោរពព្រះជាម្ចាស់ឲ្យសមនឹងឋានៈព្រះអង្គ

យើងរាល់គ្នាបានរមិលគុណចំពោះព្រះសម្រាប់អ្វីៗទាំងអស់ ដែលទ្រង់បានប្រទានឲ្យយើងនៅលើផែនដីនេះ ដូចជាកូនខូចបានរមិលគុណចំពោះឪពុកម្តាយរបស់ខ្លួន ។ យើងមិនបានផ្តល់កិត្តិយសដល់ព្រះដែលទ្រង់ត្រូវទទួលទេ ។ ផ្ទុយទៅវិញ យើងបានធ្វើរូបចម្លាក់ជាច្រើន ហើយបានថ្វាយបង្គំរូបចម្លាក់ទាំងនោះជំនួសព្រះជាម្ចាស់ ។ យើងទាំងអស់គ្នាបានឲ្យតម្លៃទៅលើអ្វីៗទាំងឡាយនៅក្នុងពិភពលោកនេះ ខ្ពស់ជាងព្រះជាម្ចាស់ ។ យើងចង់បានរបស់ដែលព្រះជាម្ចាស់បានបង្កើតមក ប៉ុន្តែមិនចង់បានព្រះដែលបានបង្កើតរបស់ទាំងនោះឡើយ ។

> **ព្រោះកាលគេបានស្គាល់ព្រះ នោះគេមិនបានតំកើងទ្រង់ ទុកជាព្រះទេ ក៏មិនដឹងគុណទ្រង់ដែរ គេកើតមានគំនិតឥតប្រយោជន៍វិញ ហើយចិត្តគេ ដែលឥតយោបល់ ក៏បានត្រឡប់ជាងងឹតទៅ ។** (*រ៉ូម ១:២១*)

ខ. យើងត្រូវការរួចពីបាប ពីព្រោះយើងមិនបានស្តាប់បង្គាប់ព្រះជាម្ចាស់

យើងរាល់គ្នាបានបះបោរប្រឆាំងនឹងបញ្ញត្តិ ដែលព្រះជាម្ចាស់បានបង្គាប់មក ។ យើងបានភូតកុហក មិនគោរពប្រតិបត្តិឪពុកម្តាយ ប្រព្រឹត្តសហាយស្មន់ លួចរបស់របរអ្នកដទៃ មានចិត្តខឹងនិងស្អប់អ្នកជិតខាង ហើយយើងមានចិត្តលោភលន់ចង់បានទ្រព្យសម្បត្តិអ្នកដទៃ ។ល។

**គេប្រកាន់ថា គេស្គាល់ព្រះ តែកិរិយាប្រព្រឹត្តរបស់គេមិនព្រមស្គាល់ព្រះទេ ដ្បិតគេជាមនុស្សគួរខ្ពើម ហើយរឹងចចេស គឺជាមនុស្សឥតមានប្រយោជន៍អ្វីដល់ការល្អទាំងអស់ ។** (*ទីតុស ១:១៦*)

គ. យើងត្រូវការរួចពីបាប ពីព្រោះយើងមានចិត្តអាត្មានិយម និងអំនួតចំពោះព្រះ និងអ្នកដទៃ

យើងរាល់គ្នាមិនបានស្រឡាញ់ព្រះជាម្ចាស់ឲ្យអស់ពីដួងចិត្តរបស់យើងនោះទេ ហើយក៏មិនបានស្រឡាញ់អ្នកដទៃដូចជាខ្លួនយើងដែរ (សូមមើលព្រះគម្ពីរម៉ាថាយ ២២:៣៦-៣៩) ។ យើងមានចិត្តចង់ពឹងលើខ្លួនឯង មិនចង់ពឹងលើព្រះដែលបានបង្កើតយើងមកនោះទេ ។ ដោយសារមនុស្សទាំងអស់គ្នាមានចិត្តអាត្មានិយម យើងគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន មិនបានគិតដល់អ្នកឯទៀតទេ ។

**យើងទាំងអស់គ្នាបានទាសចេញដូចជាចៀម គឺយើងបានបែរចេញទៅតាមផ្លូវយើងរៀងខ្លួន ។** (*អេសាយ ៥៣:៦*)

ដោយសារព្រះជាម្ចាស់មានលក្ខណៈល្អបរិសុទ្ធ និងយុត្តិធម៌ ទ្រង់មិនអាចមើលរំលងនូវអំពើបាបរបស់យើងបានឡើយ ។ តាមពិត ព្រះពេញទៅដោយសេចក្ដីក្រោធចំពោះអំពើបាបរបស់យើង ។ ដោយសារព្រះជាម្ចាស់មិនអាចប្រឆាំងនឹងលក្ខណៈយុត្តិធម៌របស់ទ្រង់ ហេតុនោះហើយបានជារាល់អំពើបាបរបស់យើងត្រូវតែមានការសងថ្លៃ ។ បើសិនជាយើងចង់សងថ្លៃរាល់អំពើបាបរបស់ខ្លួន នោះយើងនឹងត្រូវសងថ្លៃអំពើបាបរបស់យើងនៅក្នុងបឹងភ្លើងជារៀងរហូត ដ្បិតអំពើបាបរបស់យើងអាក្រក់ហួសប្រមាណនឹងអាចសងរួច ។ យើងមិនអាចសងថ្លៃអំពើបាបទាំងអស់របស់យើងបានទេ ទោះក្នុងរយៈពេលមួយឆ្នាំ មួយរយឆ្នាំ ឬក៏មួយលានឆ្នាំក៏ដោយ ។ មនុស្សទាំងអស់ដែលធ្លាក់ចូលទៅក្នុងឋាននរកមិនអាចចេញមកវិញបានទេ ពីព្រោះតែគ្មាននរណាម្នាក់អាចនឹងសងថ្លៃអំពើបាបរបស់ខ្លួនបានឡើយ គឺពួកគេត្រូវតែរងទុក្ខអស់កល្បជានិច្ចក្នុងបឹងភ្លើង ។

**តែត្រង់ពួកខ្លាច ពួកមិនជឿ ពួកគួរខ្ពើម ពួកកាប់សម្លាប់គេ ពួកកំផិត ពួកមន្តអាគម ពួកថ្វាយបង្គំរូបព្រះ ហើយគ្រប់ទាំងមនុស្សកំភូត គេនឹងមានចំណែកនៅក្នុងបឹងដែលឆេះជាភ្លើង និងស្ពាន់ធ័រ គឺជាសេចក្ដីស្លាប់ទី២វិញ ។** (*វិវរណៈ ២១:៨*)

បើសិនជាលោកអ្នកខំប្រឹងដើរតាមផ្លូវសុចរិតរបស់ខ្លួនឯង ឬក៏តាមផ្លូវសាសនា នោះតែងតែខ្វះ មិនដល់សិរីល្អនៃព្រះ ។ យើងមិនអាចធ្វើបុណ្យណា ដើម្បីក្លាយជាសុចរិតនៅចំពោះព្រះអង្គ

បានឡើយ ។ ដើម្បីសុចរិតដោយការប្រព្រឹត្ត យើងរាល់គ្នាត្រូវកាន់តាមក្រឹត្យវិន័យរបស់ព្រះទាំងមូល ពេញមួយជីវិត ហើយក៏ត្រូវកើតមកពីមាតាបិតាដែលគ្មានអំពើបាបដែរ ។ តែគ្មានមនុស្សណាម្នាក់សុចរិតដូចបែបនេះឡើយ ។

**ដ្បិតអ្នកណាដែលកាន់ក្រឹត្យវិន័យទាំងមូល តែភ្លាត់ជំពប់នឹងបទណាមួយ នោះក៏ត្រូវឡប់ជាមានទោសចំពោះក្រឹត្យវិន័យទាំងមូលនោះហើយ ។** (*យ៉ាកុប ២:១០*)

**ឧទាហរណ៍ ៖** បើយើងមានកែវទឹក២ ហើយកែវទឹកទី១មានទឹកសុទ្ធ៥០% និងថ្នាំពុល ៥០% តើលោកអ្នកចង់ផឹកទឹកពីកែវទឹកទី១នោះឬទេ ? អត់ទេ ! ហេតុអ្វី ? ពីព្រោះថ្នាំពុលនៅក្នុងកែវទឹកនោះនឹងសម្លាប់យើងតែម្ដង ។ ដូច្នេះ បើសិនជាកែវទឹកទី២មានទឹកសុទ្ធ៩៩% និងមានថ្នាំពុលតែ១%ប៉ុណ្ណោះ តើលោកអ្នកនៅតែចង់ផឹកទឹកពីកែវទឹកទី២នោះទៀតឬទេ? អត់ទេ ! សូម្បីតែមួយតំណក់ក៏ដោយ ក៏យើងនៅតែមិនចង់ផឹកទឹកពីកែវទឹកនោះដដែល ព្រោះយើងដឹងថា ថ្នាំពុលមួយតំណក់នោះនឹងធ្វើឲ្យយើងមានគ្រោះថ្នាក់មួយយ៉ាងធំ ។

ឧទាហរណ៍ដែលបានរៀបរាប់ខាងលើ គឺជាការប្រៀបធៀបមួយអំពីមនុស្សយើង និងព្រះជាម្ចាស់ដូចតទៅ ៖

- កែវទឹក = មនុស្សយើង
- ទឹកសុទ្ធ = ការប្រព្រឹត្តិល្អរបស់យើង
- ថ្នាំពុល = អំពើបាបរបស់យើង
- អ្នកដែលផឹកទឹកពីកែវទឹក = ព្រះជាម្ចាស់

ដូចជាយើងមិនអាចផឹកទឹកពីកែវទឹកដែលមានលាយថ្នាំពុលតែមួយតំណក់នោះជាយ៉ាងណា ក៏ព្រះជាម្ចាស់មិនអាចទទួលយើងជាអ្នកមានបាបបានយ៉ាងនោះដែរ ។

**សុភាសិតខ្មែរ ៖** មានសុភាសិតខ្មែរមួយដ៏ល្បីដែលមានអត្ថន័យស្រដៀងនឹងព្រះគម្ពីរយ៉ាកុប ២:១០ និងឧទាហរណ៍ខាងលើអំពីកែវទឹក ៖

«ធ្វើបុណ្យមួយរយសំពៅ បាបមួយចូលទៅរលាយបាត់អស់»

សុភាសិតនេះមានន័យថា អំពើបាបតែបន្តិចនឹងបង្ខូចដល់ទំនាក់ទំនងរវាងសាច់ញាតិ បងប្អូន អ្នកជិតខាង និងមិត្តភក្តិ ព្រមទាំងជីវិតរបស់ខ្លួនផងដែរ ។

ដូច្នេះ ដោយសារមនុស្សយើងមិនអាចរកអ្វីមកសងថ្លៃលោះបាបរបស់ខ្លួនឯងបាន តើយើងត្រូវធ្វើយ៉ាងដូចម្ដេច ដើម្បីរួចពីអំពើបាបរបស់យើង ? តើមាននរណាម្នាក់ផ្សេងទៀតអាចសងថ្លៃលោះបាបរបស់

យើងបានទេឬ ?

## ២. តើនរណាអាចលើកលែងទោសអំពើបាបរបស់យើងបាន ?

មានតែព្រះជាម្ចាស់តែប៉ុណ្ណោះ ដែលអាចលើកលែងទោសរាល់អំពើបាបរបស់យើងបាន ពីព្រោះអំពើបាបដែលយើងបានប្រព្រឹត្តប្រឆាំងនឹងព្រះអង្គ ។ គឺព្រះជាម្ចាស់នោះហើយដែលបាន សម្រេចព្រះទ័យយាងចុះពីឋានសួគ៌ យកនិស្ស័យជាមនុស្ស ហើយមកគង់នៅលើផែនដីនេះ ដើម្បី ធ្វើជាផ្លូវតែមួយសម្រាប់យើងទាំងអស់គ្នាអាចទទួលការលើកលែងទោសបាបរបស់យើងបាន ។ នៅ ពេលដែលព្រះអង្គបានយាងចុះមកនៅលើផែនដីនេះ ទ្រង់បានយកព្រះនាមពិសេសមួយគឺ *យេស៊ូវ* ដែលមានន័យថា *ព្រះជាម្ចាស់ជាទីសង្គ្រោះ* ។ ព្រះយេស៊ូវបានបំពេញគ្រប់ទាំងច្បាប់នៃព្រះជំនួស យើង ព្រោះយើងរាល់គ្នាធ្វើមិនបាន ។ ដោយសារព្រះយេស៊ូវមិនដែលធ្វើបាបណាមួយឡើយ ហើយបានគាប់ព្រះហឫទ័យព្រះវរបិតាក្នុងគ្រប់កិច្ចការទាំងអស់ ទើបទ្រង់អាចសងថ្លៃលោះបាបទាំង អស់របស់យើងបាន ។ មនុស្សផ្សេងទៀត (ដូចជាអ្នកដឹកនាំសាសនាលោកិយជាដើម) មិនអាច សងថ្លៃលោះបាបរបស់យើងបានទេ ព្រោះអ្នកទាំងអស់នោះជាអ្នកមានបាបដូចយើងដែរ ។

ព្រះយេស៊ូវមិនសមនឹងបានទទួលរងនូវការធ្វើគត់ឡើយ តែដោយសារសេចក្ដីស្រឡាញ់ របស់ព្រះអង្គ ទ្រង់បានជ្រើសរើសលះបង់ជីវិតជំនួសយើងគ្រប់ៗគ្នា ។ ព្រះយេស៊ូវបានទទួលយក នូវរាល់អំពើបាបរបស់យើង ដាក់លើរូបអង្គទ្រង់ ខណៈពេលដែលទ្រង់នៅលើឈើឆ្កាង ។ ទ្រង់បាន ទទួលនូវការឈឺចាប់ដ៏លើសលប់ ទាំងរូបកាយ ទាំងវិញ្ញាណ ជំនួសយើងគ្រប់ៗគ្នា ។ សេចក្ដីក្រោធ នៃព្រះចំពោះអំពើបាបរបស់យើងបានចាក់ស្រោចមកលើទ្រង់ ។ នេះគឺជាការសម្ដែងនូវសេចក្ដី ស្រឡាញ់ដ៏ក្រៃលែងនៅក្នុងប្រវត្តិលោកិយ គឺការសុខចិត្តស្លាប់ជំនួសសត្រូវផ្ទាល់ខ្លួន ! លោក អេសាយបានទាយប្រមាណ៧០០ឆ្នាំមុនគ.ស (២០០ឆ្នាំមុនព.ស) ថា ៖

> **តែទ្រង់ត្រូវរបួស ដោយព្រោះអំពើរំលងរបស់យើង ក៏ត្រូវវាយជាំ ដោយព្រោះ អំពើទុច្ចរិតរបស់យើងទេ ឯការវាយផ្ចាលដែលនាំឲ្យយើងបានជាមេត្រី នោះបានធ្លាក់ ទៅលើទ្រង់ ហើយយើងរាល់គ្នាបានប្រោសឲ្យជា ដោយសារស្នាមរំពាត់នៅអង្គ ទ្រង់ ។ យើងទាំងអស់គ្នាបានទាសចេញដូចជាចៀម គឺយើងបានបែរចេញទៅតាម ផ្លូវយើងរៀងខ្លួន ហើយព្រះយេហូវ៉ាបានទំលាក់អំពើទុច្ចរិតរបស់យើងទាំងអស់គ្នាទៅ លើទ្រង់ ។** (*អេសាយ ៥៣:៥-៦*)

បន្ទាប់ពីព្រះយេស៊ូវសុគត និងរស់ឡើងវិញ លោកប៉ុលបានបញ្ជាក់យ៉ាងច្បាស់អំពីសេចក្តីស្រឡាញ់ដ៏ក្រៃលែងរបស់ព្រះថា ៖

> **ដ្បិតកាលយើងនៅខ្សោយនៅឡើយ លុះដល់កំណត់ហើយ នោះព្រះគ្រីស្ទទ្រង់បានសុគតជំនួសមនុស្សទមិលល្មើស ។ កម្រនឹងមានអ្នកណាព្រមស្លាប់ជំនួសមនុស្សសុចរិតណាស់ ប៉ុន្តែប្រហែលជាមានអ្នកខ្លះហ៊ានស្លាប់ជំនួសមនុស្សល្អដែរទេដឹង ។ តែឯព្រះ ទ្រង់សម្តែងសេចក្តីស្រឡាញ់របស់ទ្រង់ ដល់យើងរាល់គ្នាឲ្យឃើញច្បាស់ ដោយព្រះគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា នោះគឺក្នុងកាលដែលយើងនៅមានបាបនៅឡើយផង ។ ដូច្នេះ ដែលបានរាប់ជាសុចរិត ដោយសារព្រះលោហិតទ្រង់ នោះប្រាកដជាយើងនឹងបានរួចចេញពីសេចក្តីក្រោធ ដោយសារទ្រង់ជាមិនខានលើសទៅទៀត ។ ដ្បិតកាលយើងជាខ្មាំងសត្រូវ បើយើងបានជាមេត្រីនឹងព្រះវិញទៅហើយ ដោយព្រះរាជបុត្រាទ្រង់សុគត ដូច្នេះ ដែលយើងបានជាមេត្រីហើយ នោះប្រាកដជាយើងនឹងបានសង្គ្រោះជាមិនខានលើសទៅទៀត ដោយទ្រង់មានព្រះជន្មរស់ឡើងវិញ ។** (*រ៉ូម ៥:៦-១០*)

ខគម្ពីរទាំងពីរនេះបានពន្យល់ប្រាប់យើងអំពីកិច្ចការ ដែលព្រះយេស៊ូវបានធ្វើសម្រាប់យើងកាលទ្រង់នៅលើឈើឆ្កាង ។ ព្រះយេស៊ូវបានលះបង់ព្រះជន្មទ្រង់ ដើម្បីបើកផ្លូវឲ្យយើងបានសង្គ្រោះរួចពីបាប ។ យើងត្រូវតែមកគាល់ព្រះជាម្ចាស់តាមព្រះហឫទ័យ និងគម្រោងការរបស់ព្រះអង្គ មិនមែនតាមផ្លូវដែលយើង ឬមនុស្សឯទៀតបានបង្កើតនោះឡើយ (ឧទាហរណ៍ ៖ តួអង្គសាសនាផ្សេងៗ) ។ ព្រះយេស៊ូវគឺជាផ្លូវតែមួយគត់ ដែលព្រះជាម្ចាស់បានប្រទានឲ្យយើង ដើម្បីរួចពីបាប ។

> **ហើយគ្មានសេចក្តីសង្គ្រោះ ដោយសារអ្នកណាទៀតសោះ ដ្បិតនៅក្រោមមេឃ គ្មាននាម ឈ្មោះ ណា ទៀត បាន ប្រទាន មក មនុស្ស ឲ្យ យើង រាល់ គ្នា បាន សង្គ្រោះ នោះឡើយ ។** (*កិច្ចការ ៤:១២*)

ព្រះជាម្ចាស់មិនមែនគ្រាន់តែប្រោសយើងឲ្យរួចពីជំងឺនៃអំពើបាបដោយការលើកលែងទោសនូវអំពើបាបរបស់យើងប៉ុណ្ណោះទេ (ការនេះបង្ហាញពីសេចក្តីមេត្តាករុណារបស់ព្រះ) តែទ្រង់ក៏បានប្រទានឲ្យយើងនូវមរតកមួយដែលឋិតថេរអស់កល្បជានិច្ចផងដែរ (ការនេះបង្ហាញពីព្រះគុណរបស់ព្រះ) ។

## សេចក្ដីសន្យាទី២ ៖ ព្រះយេស៊ូវនឹងប្រទានមរតកឲ្យយើង

អស់អ្នកដែលជឿលើព្រះយេស៊ូវនឹងទទួលមរតកពីព្រះអង្គ ។ នេះគឺជាសេចក្ដីសន្យាទី២របស់ព្រះ ។ នៅពេលដែលយើងនិយាយអំពីមរតក យើងតែងតែគិតពីទ្រព្យសម្បត្តិ ឬលុយកាក់ ដែលឪពុកម្ដាយបានបន្សល់ទុកឲ្យសម្រាប់កូនចៅរបស់ខ្លួន ។ ដូច្នេះ មរតកគឺជារបស់ទ្រព្យដែលយើងមិនបានរក តែវាជារបស់ទ្រព្យដែលអ្នកផ្សេងបានបន្សល់ទុកឲ្យ ។ ព្រះជាម្ចាស់បានប្រទានមរតកដល់កូនរបស់ទ្រង់ ។ ដូច្នេះ យើងមិនបានខិតខំរកមរតកនេះទេ ព្រោះព្រះយេស៊ូវជាអ្នកដែលបានរកមរតកនោះសម្រាប់យើងតាមរយៈព្រះជន្ម និងការសុគតរបស់ទ្រង់នៅលើឈើឆ្កាង ។ មរតកនេះមាន២ផ្នែកគឺ ៖ **របស់បញ្ចាំចិត្តនៃមរតក** ដែលយើងនឹងទទួលបានខណៈពេលដែលយើងកំពុងរស់នៅ និង**មរតកពេញលេញ** ដែលយើងនឹងទទួលក្រោយពេលយើងស្លាប់ ។

### ១. តើរបស់បញ្ចាំចិត្តនៃមរតករបស់អ្នកជឿគឺជាអ្វី ?

ព្រះគម្ពីរព្រះយេស៊ូវបានបង្រៀនថា ព្រះបានប្រទានឲ្យអ្នកជឿថ្មីនូវទ្រព្យសម្បត្តិមួយដ៏មានតម្លៃខ្ពស់ជាងគេបំផុតគឺ **ព្រះវិញ្ញាណបរិសុទ្ធនៃព្រះនឹងយាងមកសណ្ឋិតនៅជាមួយអ្នកជឿ** ។ នេះគឺជាការសន្យាដ៏អស្ចារ្យ ! ព្រះវិញ្ញាណបរិសុទ្ធជារបស់បញ្ចាំចិត្តមួយដែលជាភស្តុតាងបង្ហាញយើងថាមានមរតកបន្ថែមទៀតនឹងប្រទានឲ្យនៅពេលក្រោយ ។ ព្រះវិញ្ញាណនៃព្រះនឹងយាងមកគង់នៅជាមួយពួកអ្នកជឿលើទ្រង់ គឺក្នុងខណៈពេលដែលយើងចាប់ផ្ដើមកែប្រែចិត្តពិត និងបានជឿទុកចិត្តលើព្រះយេស៊ូវ ។

> **ឯអ្នករាល់គ្នា ក៏បានឮព្រះបន្ទូលនៃសេចក្ដីពិត គឺជាដំណឹងល្អពីសេចក្ដីសង្គ្រោះរបស់អ្នករាល់គ្នាដោយសារទ្រង់ដែរ ហើយកាលអ្នករាល់គ្នាបានជឿហើយ នោះទ្រង់ក៏ដៅចំណាំដោយព្រះវិញ្ញាណបរិសុទ្ធ ដែលបានសន្យា ព្រះវិញ្ញាណនោះទ្រង់ជាទីបញ្ចាំចិត្តពីដំណើរកេរ្តិ៍អាកររបស់យើងរាល់គ្នា ។** (*អេភេសូរ ១:១៣-១៤*)

តើការគង់នៅនៃព្រះវិញ្ញាណបរិសុទ្ធនោះ មានផលប្រយោជន៍អ្វីខ្លះចំពោះយើង*នៅពេលឥឡូវនេះ* ?

#### ក. ព្រះវិញ្ញាណបរិសុទ្ធប្រទានឲ្យយើងនូវជីវិតអស់កល្បជានិច្ចនៅពេលឥឡូវនេះ

ព្រះយេស៊ូវបានប្រទានជីវិតរបស់ទ្រង់ដល់យើង ដើម្បីនៅពេលណាដែលយើងស្លាប់ខាងរូបកាយទៅ យើងអាចទៅរស់នៅជាមួយទ្រង់នៅឋានសួគ៌បាន ។ រូបកាយរបស់យើងនឹងនៅតែស្លាប់ ដោយសារការជំនុំជម្រះរបស់ព្រះជាម្ចាស់លើមនុស្សព្រោះអំពើបាបរបស់ជីដូនជីតារបស់យើង (សូមមើលព្រះគម្ពីរលោកុប្បត្តិ ៣:១៩) ប៉ុន្តែព្រលឹងវិញ្ញាណរបស់យើងនឹងមិន

ដែលស្លាប់ឡើយ ។ អស់អ្នកដែលបានជឿលើព្រះយេស៊ូវ ហើយកែប្រែចិត្តពិតប្រាកដ មិនត្រូវខ្លាចសេចក្ដីស្លាប់ទៀតឡើយ ដ្បិតព្រះជាម្ចាស់បានប្រទានឲ្យយើងនូវជីវិតអស់កល្បជានិច្ចរួចទៅហើយ ។

**ឯអ្នកណាដែលជឿដល់ព្រះរាជបុត្រា នោះមានជីវិតដ៏នៅអស់កល្បជានិច្ចហើយ តែអ្នកណាដែលមិនព្រមជឿដល់ព្រះរាជបុត្រាវិញ នោះនឹងមិនឃើញជីវិតសោះឡើយ គឺសេចក្ដីក្រោធរបស់ព្រះតែងនៅជាប់លើអ្នកនោះឯង ។** (*យ៉ូហាន ៣:៣៦*)

មនុស្សនៅក្នុងលោកិយនេះមានការភ័យខ្លាចចំពោះសេចក្ដីស្លាប់ណាស់ ។ មនុស្សភាគច្រើនគិតថា វាគឺជាសំណាងអាក្រក់ បើគ្រាន់តែនិយាយពីសេចក្ដីស្លាប់នោះ ។ មនុស្សជាច្រើនបានចំណាយប្រាក់កាសច្រើន ដើម្បីព្យាយាមការពារខ្លួនពីគ្រោះថ្នាក់ និងពីជំងឺរោគាផ្សេងៗ ដោយការទិញខ្សែចង្កេះ ខ្សែសីមា ព្រលែងសត្វ ឬសាក់យ័ន្តជាដើម ។ ហេតុអ្វីពួកគេធ្វើដូច្នេះ ? គឺព្រោះតែពួកគេមានការភ័យខ្លាចចំពោះគ្រោះថ្នាក់ ឬសេចក្ដីស្លាប់ ដែលអាចកើតឡើងនៅក្នុងជីវិតរបស់គេ ដោយគេគ្មានអ្វីពឹងអាងក្រៅពីការទាំងអស់នេះឡើយ ! អស់អ្នកណាដែលមានជីវិតដ៏នៅអស់កល្បជានិច្ចមិនត្រូវខ្លាចសេចក្ដីស្លាប់ឡើយ ព្រោះសេចក្ដីស្លាប់ខាងរូបកាយគឺជាការត្រឡប់ទៅឯព្រះនៅឋានសួគ៌ ។ អ្នកជឿលើព្រះយេស៊ូវមានការសោកស្ដាយនៅពេលដែលមានអ្នកជឿលើព្រះយេស៊ូវម្នាក់ទទួលមរណភាព តែយើងជាកូនរបស់ព្រះមិនគួរមានសេចក្ដីសោកសង្រេងដូចជាលោកិយនោះឡើយ ដ្បិតយើងដឹងពីកន្លែងដែលអ្នកជឿទទួលមរណភាពនោះត្រូវទៅ ហើយក៏ដឹងថា យើងនឹងជួបពួកគេសាជាថ្មីម្ដងទៀតនៅទីនោះផងដែរ ។

**បងប្អូនអើយ ខ្ញុំមិនចង់ឲ្យអ្នករាល់គ្នាឥតដឹងពីពួកអ្នកដែលដេកលក់ (*ស្លាប់*) ទៅហើយទេ ក្រែងអ្នករាល់គ្នាកើតទុក្ខព្រួយ ដូចជាអ្នកឯទៀតដែលគ្មានសង្ឃឹម ។** (*១ថែស្សាឡូនីច ៤:១៣*)

មិនតែប៉ុណ្ណោះសោត អស់អ្នកណាដែលជឿលើព្រះយេស៊ូវមិនត្រូវខ្លាចវិញ្ញាណអាក្រក់ដូចជាព្រាយខ្មោច ឬអារក្សអ្នកតាជាដើមនោះឡើយ ដ្បិតព្រះវិញ្ញាណនៃព្រះដែលមានអំណាចលើសលប់នោះ រស់នៅក្នុងខ្លួនអ្នកជឿទាំងនោះ !

ពួកកូនតូចៗអើយ អ្នករាល់គ្នាមកពីព្រះ ហើយក៏ឈ្នះវិញ្ញាណទាំងនោះដែរ ពីព្រោះព្រះដែលគង់ក្នុងអ្នករាល់គ្នា នោះទ្រង់ធំជាងអានោះ ដែលនៅក្នុងលោកិយផង ។ (*១យ៉ូហាន ៤:៤*)

**ខ. ព្រះវិញ្ញាណបរិសុទ្ធបំផ្លាស់បំប្រែចិត្ត ហើយនិងការប្រព្រឹត្តិរបស់យើងនៅពេលឥឡូវនេះ !**

ព្រះវិញ្ញាណបរិសុទ្ធមកគង់នៅជាមួយយើង ដើម្បីបំផ្លាស់ចិត្តគំនិតរបស់យើង ហើយនាំយើងឲ្យរស់នៅក្នុងសេរីភាពផុតពីអំណាចនៃអំពើបាប ។ សាសនាផ្សេងៗរបស់លោកិយបានបង្រៀនយើងអំពីការចាំបាច់នៃការកែប្រែចេញពីផ្លូវបាប ក៏ប៉ុន្តែសាសនាមិនអាចជួយយើងឲ្យផ្លាស់ប្រែបាននោះទេ ! សាសនាអាចអប់រំមនុស្សឲ្យធ្វើល្អ ក៏ប៉ុន្តែគ្មានអំណាចអាចផ្លាស់ប្ដូរចិត្តរបស់យើងបានឡើយ ។ យើងត្រូវការការផ្លាស់ប្ដូរ មិនមែនត្រឹមតែការអប់រំនោះទេ ! យើងរាល់គ្នាខ្វះសមត្ថភាពធ្វើការផ្លាស់ប្ដូរចិត្ត និងគាប់ព្រះហឫទ័យព្រះ ។ យើងទាំងអស់គ្នាត្រូវការចិត្តថ្មី និងជីវិតថ្មី ដែលមានតែព្រះជាម្ចាស់ទេ ដែលអាចប្រទានឲ្យយើងបាន ។ ព្រះគម្ពីរបានបង្រៀនច្បាស់លាស់ថា ខណៈពេលដែលយើងចាប់ផ្ដើមទុកចិត្តជឿលើព្រះយេស៊ូវ យើងបានកើតជាថ្មី ហើយព្រះវិញ្ញាណបរិសុទ្ធប្រទានឲ្យយើងនូវចិត្តថ្មី ។

**បើអ្នកណានៅក្នុងព្រះគ្រីស្ទ នោះឈ្មោះថា បានកើតជាថ្មីហើយ អស់ទាំងសេចក្ដីចាស់បានកន្លងបាត់ទៅ មើល គ្រប់ទាំងអស់បានត្រឡប់ជាថ្មីវិញ ។** (*២កូរិនថូស ៥:១៧*)

នៅពេលដែលយើងមានព្រះវិញ្ញាណនៃព្រះក្នុងខ្លួនហើយ ទ្រង់នឹងបង្រៀនយើងឲ្យស្គាល់ព្រះ ហើយមានសេចក្ដីប្រកបជាមួយនឹងព្រះអង្គនៅពេលឥឡូវនេះ ។ ព្រះអង្គបង្រៀនយើងឲ្យចេះលះបង់អំពើបាបដែលយើងធ្លាប់ប្រព្រឹត្ត ហើយនាំយើងឲ្យស្គាល់សេចក្ដីអំណរ និងសេចក្ដីសុខសាន្តដ៏ពិតរបស់ទ្រង់ ។ អស់អ្នកណាដែលពិតជាប្រែចិត្ត ហើយជឿពិតប្រាកដទៅលើព្រះយេស៊ូវនឹងមានការផ្លាស់ប្ដូរក្នុងជីវិត ព្រោះព្រះវិញ្ញាណនៃព្រះដែលគង់នៅជាមួយពួកគាត់ ទ្រង់នឹងជួយអ្នកនោះឲ្យផ្លាស់ប្ដូរបន្តិចម្ដងៗដោយព្រះគុណរបស់ព្រះអង្គ ។ ដូច្នេះ បើសិនជាមានមនុស្សម្នាក់គ្មានការផ្លាស់ប្ដូរសោះនៅក្នុងចិត្ត និងជីវិតរបស់គាត់ នោះមានន័យថា ព្រះវិញ្ញាណបរិសុទ្ធមិនទាន់គង់នៅជាមួយអ្នកនោះឡើយ អ្នកនោះមិនទាន់បានកើតជាថ្មីក្នុងព្រះយេស៊ូវនោះទេ ។

ម្យ៉ាងវិញទៀត ព្រះបន្ទូលនៃព្រះក៏បានពន្យល់ថា រូបកាយរបស់អ្នកជឿលើព្រះយេស៊ូវគឺជាវិហារនៃព្រះវិញ្ញាណបរិសុទ្ធផងដែរ ។ ដូច្នេះ ជីវិតរបស់យើងត្រូវតែបរិសុទ្ធ ពីព្រោះព្រះវិញ្ញាណនៃព្រះ ដែលសណ្ឋិតនៅក្នុងយើង គឺល្អបរិសុទ្ធ ។

> **តើមិនដឹងទេឬអីថា រូបកាយអ្នករាល់គ្នាជាវិហារនៃព្រះវិញ្ញាណបរិសុទ្ធ ដែលអ្នករាល់គ្នាបានទទួលមកពីព្រះ ? ហើយអ្នករាល់គ្នាមិនមែនជារបស់ផងខ្លួនទេ ដ្បិតព្រះទ្រង់បានចេញថ្លៃលោះអ្នករាល់គ្នាហើយ ដូច្នេះ ចូរតំកើងព្រះនៅក្នុងរូបកាយនៃអ្នករាល់គ្នា ។** (*១កូរិនថូស ៦:១៩-២០*)

## ២. តើមរតកពេញលេញរបស់យើងគឺជាអ្វី ?

មរតកពេញលេញរបស់អ្នកជឿលើព្រះយេស៊ូវនៅពេលអនាគតកាល គឺជាការរស់នៅជាមួយនឹងព្រះជាម្ចាស់ជារៀងរហូត ។ មរតកនៅពេលអនាគតរបស់យើង គឺយើងមិនអាចពិពណ៌នាបានឡើយ ! យើងនឹងឃើញព្រះដ៏ពិត ហើយនិងថ្វាយបង្គំទ្រង់ ព្រមទាំងរីករាយជាមួយនឹងព្រះអង្គ និងអ្នកជឿលើព្រះយេស៊ូវទាំងអស់រហូតតទៅ ។ យើងនឹងមិនបាត់បង់មរតកនេះទេ ។

> **សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលទ្រង់បានបង្កើតយើងឡើងជាថ្មី តាមសេចក្ដីមេត្តាករុណាដ៏ធំរបស់ទ្រង់ ដើម្បីឲ្យយើងរាល់គ្នាបានសេចក្ដីសង្ឃឹមដ៏រស់ ដោយសារព្រះយេស៊ូវគ្រីស្ទ ទ្រង់រស់ពីស្លាប់ឡើងវិញ ហើយឲ្យយើងបានមរដក ដែលមិនចេះពុករលួយ ក៏ឥតសៅហ្មង ហើយមិនដែលស្រពោនឡើយ ជាមរដកដែលបំរុងទុកឲ្យយើងរាល់គ្នានៅស្ថានសួគ៌ ។** (*១ពេត្រុស ១:៣-៤*)

ព្រះអង្គនឹងបង្កើតឋានសួគ៌ថ្មី និងផែនដីថ្មីសម្រាប់យើងជាកូនរបស់ទ្រង់ ដែលជាកន្លែងគ្មានការឈឺចាប់ គ្មានការរងទុក្ខវេទនា គ្មានអំពើបាប ឬសេចក្ដីស្លាប់ទៀតឡើយ ។ យើងនឹងបានជៀសផុតពីទុក្ខវេទនា ដែលមកពីបណ្ដាសានៃអំពើបាបរបស់យើងជារៀងរហូត ! ទ្រង់នឹងប្រទានពរឲ្យយើងមានរូបកាយមួយថ្មីដែលគ្មានអំពើបាប ហើយយើងនឹងទទួលទ្រព្យសម្បត្តិយ៉ាងបរិបូរពីព្រះវរបិតារបស់យើង ! មរតកដ៏ពេញលេញនេះគួរតែលើកទឹកចិត្តយើងឲ្យខំព្យាយាមដើរតាមទ្រង់អស់ពីដួងចិត្តរបស់យើង ព្រោះយើងមិនសមនឹងទទួលមរតកអស្ចារ្យនេះពីព្រះអង្គទេ ។

តែតាមសេចក្តីសន្យារបស់ទ្រង់ នោះយើងរាល់គ្នាទន្ទឹងចាំផ្ទៃមេឃថ្មី និងផែនដីថ្មី ដែលមានសុទ្ធតែសេចក្តីសុចរិតវិញ ដូច្នេះ ឱពួកស្ងួនភ្ងាអើយ ដែលទន្ទឹងចាំសេចក្តីទាំងនោះ ចូរមានចិត្តឧស្សាហ៍ឲ្យទ្រង់បានឃើញអ្នករាល់គ្នាជាឥតសៅហ្មង ហើយឥតកន្លែងបន្ទោសបាន ទាំងមានសេចក្តីមេត្រីផង ។ (*២ពេត្រុស ៣:១៣-១៤*)

## ការដាស់តឿនចុងក្រោយ ៖

សេចក្តីសន្យាទាំងពីរដែលយើងបានរៀបរាប់នៅក្នុងមេរៀនទី២នេះ (ការរួចពីបាប និងការទទួលមរតកនៃព្រះ) គឺជារបស់ទ្រព្យដែលលោកិយនេះ ឬសាសនាក្នុងលោកិយ មិនអាចផ្តល់ដល់មនុស្សយើងបានឡើយ ។ ការសន្យាទាំងពីរនេះមានតម្លៃខ្ពស់ជាងអ្វីៗទាំងអស់នៅលើផែនដី ដូចជាលុយកាក់ អំណាច កិត្តិយស ឬការសប្បាយ ។ ល ។ ព្រះយេស៊ូវបានរំឭកដាស់តឿនយើងថា ទ្រព្យសម្បត្តិនៅក្នុងលោកិយនេះនឹងបាត់អស់ទៅ ។ អញ្ចឹង យើងគួរតែព្យាយាមប្រមូលទ្រព្យសម្បត្តិដែលឋិតថេរជារៀងរហូតវិញ ។

កុំឲ្យប្រមូលទ្រព្យសម្បត្តិទុកសម្រាប់ខ្លួននៅផែនដី ជាកន្លែងដែលមានកន្លាត និងច្រែះស៊ីបំផ្លាញ ហើយចោរទំលុះប្លន់នោះឡើយ ត្រូវប្រមូលទ្រព្យសម្បត្តិទុកសម្រាប់ខ្លួននៅឯស្ថានសួគ៌វិញ ដែលជាកន្លែងគ្មានកន្លាត ឬច្រែះស៊ីបំផ្លាញឡើយ ក៏គ្មានចោរទំលុះ ឬប្លន់ផង ពីព្រោះសម្បត្តិទ្រព្យរបស់អ្នកស្ថិតនៅកន្លែងណា នោះចិត្តអ្នកក៏នឹងនៅកន្លែងនោះដែរ ។ (*ម៉ាថាយ ៦:១៩-២១*)

ឯលោកិយនេះ និងសេចក្តីប៉ងប្រាថ្នារបស់វា នោះកំពុងកន្លងទៅ តែអ្នកណាដែលធ្វើតាមព្រះហឫទ័យព្រះ នោះនឹងនៅជាប់អស់កល្បជានិច្ចវិញ ។ (*១យ៉ូហាន ២:១៧*)

## សំណួរមេរៀនទី២ ៖

១. តើសេចក្តីសន្យាទី១ ដែលព្រះយេស៊ូវបានសន្យាចំពោះអ្នកជឿលើទ្រង់គឺជាអ្វី ?

២. យោងតាមមេរៀននេះ ហេតុអ្វីបានជាយើងត្រូវការរួចពីបាប ? (តម្រុយ ៖ មាន៣យ៉ាង)

៣. ហេតុអ្វីបានជាព្រះជាម្ចាស់មិនអាចមើលរំលងនូវអំពើបាបរបស់យើង ?

៤. តើយើងនឹងត្រូវការពេលយូរប៉ុណ្ណាទៅ ដើម្បីសងថ្លៃលោះបាបរបស់យើងឲ្យរួច ?

៥. បើយើងចង់ត្រឡប់ជាសុចរិតដោយការប្រព្រឹត្តរបស់ខ្លួនយើង តើយើងរាល់គ្នាត្រូវកាន់តាមក្រឹត្យវិន័យរបស់ព្រះប៉ុន្មានបទ ? អញ្ចឹង តើយើងរាល់គ្នាអាចទីពឹងខ្លួន ហើយត្រឡប់ជាសុចរិតដោយការ

ប្រព្រឹត្តរបស់ខ្លួនបានដែរឬទេ ?

៦. តើអ្នកណាអាចសងថ្លៃលោះបាបរបស់យើងបាន ? ហេតុអ្វីបានជាព្រះយេស៊ូវអាចសងថ្លៃលោះបាបទាំងអស់របស់យើងបាន ប៉ុន្តែមនុស្សផ្សេងទៀតមិនអាចសងថ្លៃលោះបាបរបស់យើងបាន ?

៧. តើសេចក្ដីសន្យាទី២ ដែលព្រះយេស៊ូវបានសន្យាចំពោះអ្នកជឿលើទ្រង់គឺជាអ្វី ?

៨. មរតកនៃព្រះយេស៊ូវមានពីរផ្នែក តើមានអ្វីខ្លះ ?

៩. តើរបស់បញ្ចាំចិត្តនៃមរតករបស់យើងគឺជាអ្វី ?

១០. តើព្រះវិញ្ញាណបរិសុទ្ធនៃព្រះមកគង់នៅជាមួយអ្នកជឿនៅពេលណា ?

១១. យោងតាមមេរៀននេះ តើការគង់នៅនៃព្រះវិញ្ញាណបរិសុទ្ធនោះ មានផលប្រយោជន៍អ្វីខ្លះចំពោះយើងនៅពេលឥឡូវនេះ ? (តម្រុយ ៖ មាន២យ៉ាង)

១២. តើជីវិតដ៏នៅអស់កល្បជានិច្ចមានន័យថា រូបកាយរបស់យើងមិនចេះស្លាប់មែនឬទេ ?

១៣. តើអ្នកជឿលើព្រះយេស៊ូវគួរខ្លាចសេចក្ដីស្លាប់ដែរឬទេ ? ហេតុអ្វី ?

១៤. តើមនុស្សលោកតែងតែធ្វើអ្វីដែលបង្ហាញថា ពួកគេមានការភ័យខ្លាចចំពោះសេចក្ដីស្លាប់ ?

១៥. តើអ្នកជឿលើព្រះយេស៊ូវគួរខ្លាចវិញ្ញាណអាក្រក់ ព្រាយខ្មោច ឬអារក្សអ្នកតាដែរឬទេ ? ហេតុអ្វី ?

១៦. តើសាសនារបស់លោកិយមានអំណាចជួយផ្លាស់ប្ដូរចិត្តរបស់មនុស្សយើងដែរឬទេ ?

១៧. ហេតុអ្វីបានជាអ្នកទាំងអស់ដែលជឿលើព្រះយេស៊ូវពិតប្រាកដនឹងពិតជាមានការផ្លាស់ប្ដូរក្នុងជីវិតរបស់គេ ?

១៨. តើវិហារនៃព្រះវិញ្ញាណបរិសុទ្ធគង់នៅទីណា ?

១៩. តើមរតកពេញលេញរបស់យើងគឺជាអ្វីខ្លះ ?

២០. តើការសន្យាទាំងពីរដែលព្រះបានសន្យាប្រទានឲ្យអ្នកជឿ (ការរួចពីបាប និងការទទួលមរតកនៃព្រះ) មានតម្លៃខ្ពស់ជាងអ្វីខ្លះនៅលើផែនដីនេះ ?

# មេរៀនទី៣

## សំណួរទី៣៖ តើការកែប្រែចិត្តពិតប្រាកដ មានន័យយ៉ាងដូចម្ដេច ?

អស់អ្នកណាដែលបានទទួលការរួចពីបាប (សេចក្ដីសន្យាទី១) ហើយបានទទួលព្រះវិញ្ញាណបរិសុទ្ធនៃព្រះជាមរតកដំបូងរបស់ពួកគេ (សេចក្ដីសន្យាទី២) នឹងមានចិត្តចង់គោរព និងដើរតាមព្រះជាម្ចាស់ ។ អស់មនុស្សទាំងឡាយណាដែលមានសេចក្ដីជំនឿពិតប្រាកដទៅលើព្រះយេស៊ូវ នឹងបង្កើតផលផ្លែនៃការប្រែចិត្ត ។ ព្រះយេស៊ូវ និងសាវករបស់ទ្រង់បានថែងជាច្រើនអំពីភាពចាំបាច់នៃការកែប្រែចិត្តពីអំពើបាប និងផ្លូវចាស់របស់យើង ។ នៅពេលដែលព្រះយេស៊ូវ និងសាវករបស់ទ្រង់ប្រើពាក្យ «កែប្រែចិត្ត» នោះ តើពាក្យនោះមានន័យយ៉ាងដូចម្ដេច ? នេះគឺជាសំណួរមួយដែលមានសារៈសំខាន់ណាស់ ។

## គំរូរបស់សាវកប៉ុល ៖

មុនពេលគាត់ជឿលើព្រះយេស៊ូវ លោកប៉ុលស្អប់ ហើយបៀតបៀនដល់អ្នកជឿលើព្រះយេស៊ូវ ។ ក្រោយមក ព្រះយេស៊ូវបានបង្ហាញរូបអង្គទ្រង់ឲ្យលោកប៉ុលបានឃើញ ។ នៅពេលនោះ គាត់បានកែប្រែចិត្តជឿលើទ្រង់ ព្រមទាំងក្លាយជាអ្នកបម្រើរបស់ព្រះអង្គទៅវិញ ។ ទ្រង់បានត្រាស់ហៅគាត់ឲ្យបម្រើព្រះអង្គក្នុងការផ្សាយដំណឹងល្អទៅគ្រប់ជាតិសាសន៍ ។ សូមលោកអ្នកយកចិត្តទុកដាក់ទៅលើរបៀបដែលសាវកប៉ុលបានប្រកាសព្រះបន្ទូលនៃព្រះទៅកាន់សាសន៍ផ្សេងៗ កាលគាត់បានធ្វើទីបន្ទាល់ចំពោះស្ដេចនៅសម័យនោះ ។

> ដូច្នេះ បពិត្រព្រះរាជាអ័គ្រីប៉ាអើយ ទូលបង្គំមិនបានចចេសនឹងការជាក់ស្ដែងពីស្ថានសួគ៌នោះទេ គឺទូលបង្គំបានប្រាប់ឲ្យមនុស្សទាំងអស់ប្រែចិត្ត ហើយងាកបែរមកឯព្រះវិញ ទាំងប្រព្រឹត្តបែបសំណំនឹងការប្រែចិត្តផង គឺប្រាប់ដល់ពួកអ្នកដែលនៅក្រុងដាម៉ាសជាមុនដំបូង រួចនៅក្រុងយេរូសាឡឹម នឹងគ្រប់ក្នុងខេត្តយូដា ហើយដល់អស់ទាំងសាសន៍ដទៃផង ។ (*កិច្ចការ ២៦:១៩-២០*)

នៅពេលដែលលោកប៉ុលប្រកាសដំណឹងល្អ តើលោកបានប្រាប់ប្រជាជននៅតាមកន្លែងផ្សេងៗឲ្យធ្វើអ្វីខ្លះ ? មានសកម្មភាព៣នៅក្នុងកិច្ចការ ២៦:២០ ៖

១. គាត់បានប្រាប់មនុស្សទាំងអស់ឲ្យប្រែចិត្ត (ពីជំនឿចាស់ និងពីអំពើបាបចាស់របស់ពួកគេ) ។
២. គាត់បានប្រាប់មនុស្សទាំងអស់ឲ្យងាកបែរមកឯព្រះវិញ ។
៣. គាត់បានប្រាប់មនុស្សទាំងអស់ឲ្យប្រព្រឹត្តបែបសំណំនឹងការប្រែចិត្ត (អ្នកនោះត្រូវតែមានផលផ្លែនៃការប្រែចិត្ត) ។

**អ្នកណាដែលពិតជាប្រែចិត្ត ហើយជឿពិតប្រាកដទៅលើព្រះយេស៊ូវនោះ នឹងមានការផ្លាស់ប្តូរក្នុងជីវិត ។** ហេតុអ្វីក៏ដូច្នេះ ? ពីព្រោះពួកគេបានងាកចេញពីផ្លូវចាស់របស់ពួកគេ ដើម្បីទៅរកផ្លូវរបស់ព្រះ ហើយឥឡូវនេះ ព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយពួកគេ ហើយកំពុងតែធ្វើការផ្លាស់ប្តូរពួកគេឲ្យដូចជាព្រះយេស៊ូវវិញ ។ ព្រះគម្ពីរបានចែងថា ៖

> បើអ្នកណានៅក្នុងព្រះគ្រីស្ទ នោះឈ្មោះថាបានកើតជាថ្មីហើយ អស់ទាំងសេចក្តីចាស់បានកន្លងបាត់ទៅ មើល គ្រប់ទាំងអស់បានត្រឡប់ជាថ្មីវិញ ។ (*២កូរិនថូស ៥:១៧*)

> យើងរាល់គ្នាដឹងថា យើងស្គាល់ទ្រង់ដោយសារសេចក្តីនេះ គឺដោយយើងកាន់តាមបញ្ញត្តិរបស់ទ្រង់ ។ អ្នកណាដែលថា បានស្គាល់ទ្រង់ តែមិនកាន់តាមបញ្ញត្តិទ្រង់ទេ អ្នកនោះឈ្មោះថាជាអ្នកកុហក ហើយសេចក្តីពិតមិននៅក្នុងអ្នកនោះឡើយ តែអ្នកណាដែលកាន់តាមព្រះបន្ទូលទ្រង់វិញ នោះប្រាកដជាសេចក្តីស្រឡាញ់នៃព្រះបានពេញខ្នាតនៅក្នុងអ្នកនោះហើយ គឺដោយសេចក្តីនោះឯង ដែលយើងដឹងថា យើងនៅក្នុងទ្រង់ ។ អ្នកណាដែលថាខ្លួននៅក្នុងទ្រង់ នោះត្រូវតែប្រព្រឹត្តដូចជាទ្រង់ដែរ ។ (*១យ៉ូហាន ២:៣-៦*)

ចូរក្រឡេកមើលឧទាហរណ៍នៃអ្នកជឿលើព្រះយេស៊ូវថ្មីៗពីរក្រុម ដែលធ្វើជានិមិត្តរូបល្អអំពីការកែប្រែចិត្តចំពោះព្រះអង្គ ។

## ឧទាហរណ៍ពីរដែលបង្ហាញពីការកែប្រែចិត្តពិតប្រាកដ ៖

### ក. ឧទាហរណ៍ទី១ ៖ ពួកអ្នកជឿនៅក្នុងទីក្រុងអេភេសូរ

> ហើយព្រះទ្រង់ធ្វើការឫទ្ធិបារមីយ៉ាងប្លែកៗ ដោយសារដៃប៉ុល ដល់ម៉្លេះបានជាគេគ្រាន់តែយកកន្សែង ឬក្រមា ពីខ្លួនគាត់ ទៅដាក់លើមនុស្សមានជំងឺ នោះគេក៏បានជា

ហើយមានអារក្សអសោចិ៍ចេញពីមនុស្សដែរ ។ រីឯមានមនុស្សសាសន៍យូដាខ្លះ ជាគ្រូមន្តអាគមដែលដើរចុះឡើង គេក៏ចាប់តាំងអំពាវនាវ ដល់ព្រះនាមព្រះអម្ចាស់យេស៊ូវពីលើមនុស្សដែលមានអារក្សអសោចិ៍ចូលថា អញបង្គាប់ឯង ដោយនូវព្រះយេស៊ូវដែលប៉ុលប្រកាសប្រាប់នោះ ។ ក្នុងពួកមនុស្សដែលធ្វើដូច្នោះ មាន៧នាក់ ជាកូននៃសាសន៍យូដាម្នាក់ ដែលធ្វើជាសង្គ្រាជឈ្មោះស្កេវ៉ា តែអារក្សអសោចិ៍ឆ្លើយទៅគេថា យើងស្គាល់ព្រះយេស៊ូវហើយ ក៏ស្គាល់ប៉ុលបន្តិចបន្តួចដែរ តែឯងឯងរាល់គ្នា តើជាអ្នកណាវិញ ? រួចមនុស្សដែលមានអារក្សអសោចិ៍ចូលក៏ស្ទុះទៅលើគេ ទាំងបង្រ្កប ហើយឈ្នះគេ ដល់ម្ល៉េះបានជាគេរត់ចេញពីផ្ទះនោះទាំងអាក្រាត ហើយមានរបួសផង ។ ឯអស់មនុស្សនៅក្រុងអេភេសូរ ទាំងសាសន៍យូដា នឹងសាសន៍ក្រេកផង បានដឹងរឿងនោះ ក៏កើតមានចិត្តភ័យខ្លាចទាំងអស់គ្នា ហើយព្រះនាមព្រះអម្ចាស់យេស៊ូវក៏បានថ្កើងឡើង ។ មានមនុស្សជាច្រើនដែលបានជឿ គេមកលន់តួ ព្រមទាំងសម្តែងប្រាប់ពីការដែលខ្លួនបានប្រព្រឹត្តផង ។ ឯមនុស្សដែលប្រព្រឹត្តវិជ្ជាប្លែកៗ នោះក៏មានច្រើននាក់ បានយកក្បួនតម្រារបស់ខ្លួន មកដុតចោលនៅចំពោះមុខមនុស្សទាំងអស់គ្នា ។ គេបានគិតថ្លៃក្បួនទាំងនោះមើល ឃើញមានដំឡែអស់៥ម៉ឺនរៀល ។ គឺយ៉ាងដូច្នោះឯង ដែលព្រះបន្ទូលនៃព្រះអម្ចាស់បានចំរើនកើនឡើង ហើយបានឈ្នះដោយអំណាច ។ (*កិច្ចការ ១៩:១១-២០*)

អ្វីដែលបានកើតឡើងនៅទីក្រុងអេភេសូរ គឺអស្ចារ្យណាស់ ! អំណាចរបស់ព្រះជាម្ចាស់ត្រូវបានបង្ហាញដល់មនុស្សជាច្រើនតាមវិធីផ្សេងៗ ។ មនុស្សជាច្រើនបានជឿដំណឹងល្អ ដែលបានផ្សព្វផ្សាយដោយលោកប៉ុលនៅទីនោះ ។ តើពួកគេបានធ្វើអ្វី ដើម្បីបង្ហាញពីសេចក្តីជំនឿរបស់ពួកគេទៅលើព្រះយេស៊ូវ ? អ្នកជឿលើព្រះយេស៊ូវថ្មីៗនៅក្រុងអេភេសូរបានបំផ្លាញក្បួនតម្រា និងលះបង់វត្ថុសាសនាទាំងអស់របស់ពួកគេដោយដុតចោល ទោះបីជាវាមានតម្លៃស្មើនឹងលុយជាច្រើនក៏ដោយ ។ ទ្រព្យសម្បត្តិដែលគេបានបំផ្លាញចោល បើគិតជាលុយរបស់យើងសព្វថ្ងៃនេះ គឺមានតម្លៃជាង ៥០.០០០$ ! ហេតុអ្វីបានជាពួកគេធ្វើដូច្នេះ ? ពួកគេពិតជាបានប្រែចិត្ត ហើយងាកចេញពីការបម្រើព្រះមិនពិត ទៅបម្រើព្រះដ៏ពិត ដែលមានព្រះជន្មដ៏រស់វិញ ។ ឥឡូវនេះ ព្រះវិញ្ញាណបរិសុទ្ធនៃព្រះគង់នៅជាមួយពួកគេ ហេតុដូច្នេះហើយបានជាពួកគេមិនចង់ថ្វាយបង្គំវិញ្ញាណអាក្រក់និងព្រះដទៃទៀត ។

ខ. ឧទាហរណ៍ទី២ ៖ ពួកអ្នកជឿនៅក្នុងទីក្រុងថែស្សាឡូនីច

ឱបងប្អូន ដែលព្រះទ្រង់ស្រឡាញ់អើយ យើងខ្ញុំដឹងថា ទ្រង់បានរើសតាំងអ្នករាល់គ្នាហើយ ដ្បិតដំណឹងល្អរបស់យើងខ្ញុំ មិនបានផ្សាយមកដល់អ្នករាល់គ្នា ដោយពាក្យសម្ដីតែប៉ុណ្ណោះទេ គឺដោយព្រះចេស្ដា និងព្រះវិញ្ញាណបរិសុទ្ធដែរ ហើយដោយសេចក្ដីជំនឿដ៏មោះមុតជាខ្លាំងថែមទៀតផង ដូចជាអ្នករាល់គ្នាដឹងហើយ ពីដំណើរយើងខ្ញុំ ដែលនៅក្នុងពួកអ្នករាល់គ្នាជាយ៉ាងណា សម្រាប់នឹងជួយដល់អ្នករាល់គ្នា ។ អ្នករាល់គ្នាក៏បានត្រាប់តាមយើងខ្ញុំ ហើយនិងព្រះអម្ចាស់ ដោយបានទទួលព្រះបន្ទូល ដោយសេចក្ដីអំណររបស់ព្រះវិញ្ញាណបរិសុទ្ធ ក្នុងកាលដែលកំពុងតែកើតទុក្ខលំបាកជាខ្លាំងផង ដល់ម៉្លេះបានជាអ្នករាល់គ្នាបានត្រឡប់ជាគំរូ ដល់អស់អ្នកដែលជឿនៅស្រុកម៉ាសេដូន និងស្រុកអាខៃ ។ ដ្បិតព្រះបន្ទូលនៃព្រះអម្ចាស់បានផ្សាយចេញពីអ្នករាល់គ្នា មិនមែនតែក្នុងស្រុកម៉ាសេដូន និងស្រុកអាខៃប៉ុណ្ណោះទេ គឺរហូតដល់គ្រប់ទាំងកន្លែង ដែលឮនិយាយពីសេចក្ដីជំនឿរបស់អ្នករាល់គ្នាចំពោះព្រះថែមទៀតផង បានជាមិនចាំបាច់ឲ្យយើងខ្ញុំនិយាយអ្វីទៀតទេ ។ ដ្បិតគេថ្លែងប្រាប់ពីយើងខ្ញុំ ដែលអ្នករាល់គ្នាបានទទួលយើងជាយ៉ាងណា ទាំងបែរចេញពីរូបព្រះ មកឯព្រះដ៏ពិត ឲ្យបានគោរពប្រតិបត្តិដល់ព្រះ ដ៏មានព្រះជន្មរស់នៅនោះវិញ ហើយឲ្យបានចាំព្រះរាជបុត្រាព្រះ ទ្រង់យាងមកពីស្ថានសួគ៌ ដែលព្រះបានប្រោសឲ្យទ្រង់រស់ពីស្លាប់ឡើងវិញ គឺជាព្រះយេស៊ូវ ដែលទ្រង់ប្រោសឲ្យយើងរួចពីសេចក្ដីខ្ញាល់ទៅមុខ ។ (*១ថែស្សាឡូនីច ១:៤-១០*)

ទីបន្ទាល់របស់ពួកអ្នកជឿទាំងនេះនៅក្នុងទីក្រុងថែស្សាឡូនីចអស្ចារ្យណាស់ហ្ន៎ ! តើអ្វីខ្លះជាភស្តុតាងដែលបង្ហាញថា ពួកអ្នកជឿនៅក្នុងទីក្រុងថែស្សាឡូនីចពិតជាបានកែប្រែចិត្តចេញពីជំនឿចាស់ និងអំពើបាបចាស់របស់ពួកគេ ? នៅក្នុងខ៨បានចែងថា ព្រះបន្ទូល និងសេចក្ដីជំនឿរបស់អ្នកជឿនៅទីក្រុងថែស្សាឡូនីច «បានផ្សាយចេញពី» ពួកគេបានជា «មិនចាំបាច់ឲ្យយើងខ្ញុំនិយាយអ្វីទៀតទេ» ។ ខនេះមានន័យថា មនុស្សគ្រប់គ្នាបានឃើញការផ្លាស់ប្ដូរក្នុងជីវិតរបស់ពួកគេ ។

ហើយសូមពិចារណាមើលរបៀបដែលពួកគេបានបែរចេញពីរូបព្រះ ដើម្បីបម្រើព្រះដ៏ពិតដែលមានព្រះជន្មដ៏រស់ ! មានសកម្មភាព៣នៅក្នុងខ៩ ស្រដៀងនឹងសកម្មភាពទាំង៣ដែលលោកប៉ុលបានរៀបរាប់ក្នុងទីបន្ទាល់របស់គាត់នៅកិច្ចការ ២៦ ៖

១. ពួកគេបានបែរចេញពីរូបព្រះ ។
២. ពួកគេបានមកឯព្រះដ៏ពិត ។
៣. ពួកគេបានគោរពប្រតិបត្តិដល់ព្រះ ។

ពួកអ្នកជឿពិតប្រាកដទាំងអស់នៅក្នុងព្រះយេស៊ូវគ្រីស្ទបានងាកចេញពីរូបសំណាក និងផ្លូវនៃជំនឿចាស់របស់គេ ។ ពួកអ្នកជឿលើព្រះយេស៊ូវពិតប្រាកដនឹងបម្រើព្រះអង្គតែមួយប៉ុណ្ណោះ ។ គ្មានករណីលើកលែងនោះទេ ។ គ្មាននរណាម្នាក់អាចបម្រើចៅហ្វាយពីរក្នុងពេលតែមួយបានទេ ព្រោះព្រះគម្ពីរបានចែងថា ៖

> **គ្មានអ្នកណាអាចនឹងបំរើចៅហ្វាយ២នាក់បានទេ ដ្បិតអ្នកនោះនឹងស្អប់១ ហើយស្រឡាញ់១ ឬស្មោះត្រង់នឹង១ ហើយមើលងាយ១ អ្នករាល់គ្នាពុំអាចនឹងគោរពដល់ព្រះ និងទ្រព្យសម្បត្តិផងបានទេ ។** (*ម៉ាថាយ ៦:២៤*)

គម្ពីរ១ថែស្សាឡូនីច ១:៩ បានចែងថា អ្នកដែលកែប្រែចិត្តពិតប្រាកដនឹងបែរចេញពីរូបព្រះ ។ តើពាក្យ «រូបព្រះ» អាចសំដៅទៅលើអ្វីខ្លះ ? «រូបព្រះ» គឺជាអ្វីៗទាំងអស់ ទាំងរូបចម្លាក់ ទាំងវត្ថុស័ក្តិសិទ្ធិផ្សេងៗ ដែលយើងចាត់ទុកសំខាន់ជាងព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើង ។ សាវកប៉ុលបានបង្រៀនតាមរយៈព្រះវិញ្ញាណបរិសុទ្ធថា សេចក្តីលោភលន់ចាត់ទុកដូចជាការថ្វាយបង្គំរូបព្រះដែរ ដ្បិតព្រះគម្ពីរបានប្រាប់ថា ៖

> **ដូច្នេះ ចូរសម្លាប់និស្ស័យសាច់ឈាមរបស់អ្នករាល់គ្នា ដែលនៅផែនដីនេះចេញ គឺជាការសហាយស្មន់ ស្មោកគ្រោក សំរើបសំរាល ប៉ងប្រាថ្នាអាក្រក់ និងសេចក្តីលោភ ដែលរាប់ទុកដូចជាការថ្វាយបង្គំរូបព្រះ ។** (*កូឡុស ៣:៥*)

ឧទាហរណ៍ទាំងពីរនៅខាងលើបានបង្ហាញយ៉ាងច្បាស់លាស់ថា អ្នកណាដែលពិតជាប្រែចិត្ត ហើយជឿពិតប្រាកដទៅលើព្រះយេស៊ូវនោះ នឹងមានការផ្លាស់ប្តូរក្នុងជីវិត ។ ដូច្នេះ អ្នកទាំងឡាយណាដែលចង់បន្តប្រព្រឹត្តតាមផ្លូវចាស់របស់ពួកគេ ហើយបម្រើព្រះចាស់ នោះគេមិនទាន់បានកែប្រែចិត្ត និងត្រឡប់ទៅរកព្រះនៅឡើយទេ ទោះបីជាគេពោលពាក្យថា គេជឿក៏ដោយ ។ អស់អ្នកដែលមិនចង់ដើរតាមព្រះយេស៊ូវ ហើយនៅតែមានបំណងដើរក្នុងអំពើបាប ដូចជាលោកិយវិញ អ្នកនោះគ្មានព្រះវិញ្ញាណបរិសុទ្ធគង់នៅក្នុងខ្លួនទេ ។ អ្នកនោះមិនមែនជាអ្នកជឿលើព្រះយេស៊ូវដ៏ពិតនោះទេ ។ ការកែប្រែចិត្តមានន័យថា អ្នកជឿមានបំណងបែរចេញពីអំពើបាបដែលគាត់បានប្រព្រឹត្តកន្លង

មក ។ នៅពេលដែលយើងពិតជាលន់តួបាប ព្រះវិញ្ញាណនៃព្រះដ៏ជារបស់បញ្ចាំចិត្តរបស់យើង ទ្រង់នឹងជួយយើងឲ្យផ្លាស់ប្តូរបន្តិចម្តងៗដោយព្រះគុណរបស់ព្រះអង្គ គឺក្នុងន័យឲ្យយើងមានសមត្ថភាពដើរតាមព្រះយេស៊ូវបាន ។ ការទាំងអស់នេះមានន័យថា អ្នកជឿលើព្រះយេស៊ូវទាំងអស់នឹងមានចិត្តលែងប្រព្រឹត្តកិច្ចការខាងសាច់ឈាម ហើយគាត់នឹងបង្កើតផលផ្លែនៃព្រះវិញ្ញាណបរិសុទ្ធ ព្រោះព្រះគម្ពីរបានប្រាប់ថា ៖

> រីឯកិច្ចការខាងសាច់ឈាម នោះប្រាកដច្បាស់ហើយ គឺជាសេចក្តីកំផិត សហាយស្មន់ ស្មោកគ្រោក អាសអាភាស ថ្វាយបង្គំរូបព្រះ មន្តអាគម សំអប់គ្នា ឈ្លោះប្រកែក ឈ្នានីស កំហឹង ទាស់ទែងគ្នា បាក់បែក បក្សពួក ច្រណែន កាប់សម្លាប់ ប្រមឹក ស៊ីផឹកជ្រុល និងការអ្វីទៀត ដែលស្រដៀងនឹងសេចក្តីទាំងនេះផង ហើយខ្ញុំប្រាប់អ្នករាល់គ្នាទុកជាមុន ដូចជាបានប្រាប់រួចមកហើយថា អស់អ្នកដែលប្រព្រឹត្តដូច្នេះ នោះមិនបានគ្រងនគរព្រះ ទុកជាមរដកឡើយ ។ តែឯផលផ្លែនៃព្រះវិញ្ញាណវិញ នោះគឺសេចក្តីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ស្លូតបូត ហើយដឹងខ្នាត គ្មានក្រឹត្យវិន័យណាទាស់នឹងសេចក្តីយ៉ាងនោះទេ ។ ហើយអស់អ្នកដែលជារបស់ផងព្រះគ្រីស្ទ នោះបានឆ្កាងសាច់ឈាមហើយ ព្រមទាំងសេចក្តីរំជួល និងសេចក្តីប៉ងប្រាថ្នាទាំងប៉ុន្មានផង ។ បើសិនជាយើងរស់ដោយនូវព្រះវិញ្ញាណ នោះត្រូវដើរដោយព្រះវិញ្ញាណដែរ (*កាឡាទី ៥:១៩-២៥*)

## សំណួរមេរៀនទី៣ ៖

១. យោងតាមកិច្ចការ ២៦:១៩-២០ នៅពេលលោកប៉ុលបានប្រកាសដំណឹងល្អ តើគាត់បានប្រាប់ប្រជាជនឲ្យធ្វើអ្វី ? (តម្រុយ ៖ មានសកម្មភាព៣យ៉ាង)

២. ហេតុអ្វីបានជាអ្នកទាំងអស់ដែលបានកែប្រែចិត្តពិតប្រាកដនោះ នឹងមានការផ្លាស់ប្តូរក្នុងជីវិត ?

៣. តើអ្វីខ្លះជាភស្តុតាងដែលបង្ហាញថា ពួកអ្នកជឿនៅក្នុងទីក្រុងអេភេសូរពិតជាបានកែប្រែចិត្តចេញពីជំនឿចាស់ និងអំពើបាបចាស់របស់ពួកគេ ?

៤. តើអ្វីខ្លះជាភស្តុតាងដែលបង្ហាញថា ពួកអ្នកជឿនៅក្នុងទីក្រុងថែស្សាឡូនីចពិតជាបានកែប្រែចិត្តចេញពីជំនឿចាស់ និងអំពើបាបចាស់របស់ពួកគេ ?

៥. តើមនុស្សយើងអាចគោរព និងបម្រើចៅហ្វាយពីរក្នុងពេលតែមួយបានឬទេ ?

៦. យោងតាមមេរៀនរបស់យើង តើពាក្យ «រូបព្រះ» អាចសំដៅទៅលើអ្វីខ្លះ ?

៧. យោងតាមកាឡាទី ៥:១៩-២១ អ្នកទាំងឡាយណាដែលនៅតែមានចិត្តបន្តប្រព្រឹត្តកិច្ចការខាងសាច់ឈាមនៅឡើយ (ផ្លូវចាស់របស់ពួកគេ) តើពួកគេបានកែប្រែចិត្តពិតប្រាកដដែរឬទេ ?

៨. យោងតាមកាឡាទី ៥:២២-២៥ តើបទគម្ពីរនេះបានពិពណ៌នាប្រាប់យើងយ៉ាងដូចម្តេចខ្លះ ចំពោះការប្រព្រឹត្តិរបស់អ្នកដែលបានកែប្រែចិត្តរួចហើយ ?

# មេរៀនទី៤

## សំណួរទី៤ ៖ តើអ្វីជាការលះបង់ និងសេចក្តីអំណរ នៃការក្លាយជាសិស្សដ៏ពិតរបស់ព្រះយេស៊ូវ ?

*(សម្គាល់សម្រាប់គ្រូបង្រៀន ៖ ដោយសារមេរៀនទី៤នេះវែង លោកអ្នកអាចចែកជា២មេរៀនក៏បានដែរ)*

បន្ទាប់ពីមនុស្សម្នាក់បានជឿលើព្រះយេស៊ូវជាព្រះអង្គសង្គ្រោះ ហើយបានកែប្រែចិត្តពីអំពើបាបរបស់ខ្លួន នោះនៅគ្រាណាមួយ អ្នកនោះនឹងចាប់ផ្តើមជួបប្រទះសេចក្តីបៀតបៀន ។ សេចក្តីបៀតបៀននេះ គឺមិនមែនគ្រាន់តែកើតចេញពីពាក្យសម្តីប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងករណីខ្លះ សេចក្តីបៀតបៀនអាចកើតចេញពីប្រភពផ្សេងៗទៀត ដូចជាសេចក្តីច្រណែនក្នុងក្រុមគ្រួសារ ឬមិត្តភក្តិរបស់ពួកគេ ។ នៅក្នុងមេរៀននេះ យើងនឹងដឹងច្បាស់ថា សេចក្តីបៀតបៀនគឺជាបទពិសោធន៍ធម្មតារបស់អ្នកជឿលើព្រះយេស៊ូវទាំងអស់ ។

## គំរូរបស់សាវកប៉ុល ៖

នៅក្នុងមេរៀនទី៣ យើងបានសិក្សាអំពីសេចក្តីប្រកាសរបស់លោកប៉ុលចំពោះប្រជាជននៅសម័យនោះ ។ តើលោកអ្នកគិតថា មានអ្វីបានកើតឡើងចំពោះសាវកប៉ុលនៅពេលដែលគាត់បានប្រកាសប្រាប់យ៉ាងក្លាហានថា មនុស្សទាំងអស់ត្រូវកែប្រែចិត្តពីផ្លូវចាស់ ហើយងាកបែរមករកព្រះវិញ ? តើលោកអ្នកគិតថា ប្រជាជននៅសម័យនោះចូលចិត្តសេចក្តីបង្រៀននេះឬទេ ? នៅពេលដែលពួកគេបានឮថា ពួកគេមានអំពើបាបដែលប្រឆាំងនឹងព្រះពិតតែមួយ ហើយពួកគេនៅក្រោមអំណាច និងការគ្រប់គ្រងរបស់អារក្សសាតាំង ហើយត្រូវរំដោះពីអំណាចរបស់វា តើពួកគេសប្បាយចិត្តដែរឬទេ ? តើលោកអ្នកមានអារម្មណ៍យ៉ាងដូចម្តេច នៅពេលដែលលោកអ្នកបានឮដំណឹងថា មានព្រះពិតតែមួយប៉ុណ្ណោះ ហើយផ្លូវសាសនាចាស់របស់លោកអ្នក និងជីដូនជីតារបស់អ្នក គឺជាផ្លូវខុស ? ត្រង់ចំណុចខ្លះ ដំណឹងល្អរបស់ព្រះយេស៊ូវពិបាកស្តាប់ណាស់ ! ឥឡូវនេះ សូមអានពីអ្វីដែលបានកើតឡើងចំពោះសាវកប៉ុល នៅពេលគាត់បានប្រកាសពីការកែប្រែចិត្តនេះ ។

ដូច្នេះ បពិត្រព្រះរាជាអ័គ្រីប៉ាអើយ ទូលបង្គំមិនបានចចេសនឹងការជាក់ស្ដែងពីស្ថានសួគ៌នោះទេ គឺទូលបង្គំបានប្រាប់ឲ្យមនុស្សទាំងអស់ប្រែចិត្ត ហើយងាកបែរមកឯព្រះវិញ ទាំងប្រព្រឹត្តបែបសំណាំនឹងការប្រែចិត្តផង គឺប្រាប់ដល់ពួកអ្នកដែលនៅក្រុងដាម៉ាសជាមុនដំបូង រួចនៅក្រុងយេរូសាឡឹម និងគ្រប់ក្នុងខេត្តយូដា ហើយដល់អស់ទាំងសាសន៍ដទៃផង ។ ដោយហេតុនោះបានជាពួកសាសន៍យូដាចាប់ទូលបង្គំនៅក្នុងព្រះវិហារ ហើយព្យាយាមនឹងសម្លាប់ទូលបង្គំចោល ។ (*កិច្ចការ ២៦:១៩-២១*)

នៅពេលដែលសាវកប៉ុលបានអធិប្បាយ និងបង្រៀនដល់សាសន៍យូដាជាច្រើន តើអ្នកស្ដាប់បានឆ្លើយតបយ៉ាងដូចម្ដេចដែរ ? មនុស្សខ្លះបានស្អប់លោកប៉ុល ហើយបានព្យាយាមសម្លាប់គាត់ចោល ។ ហេតុនេះហើយទើបគាត់ធ្វើទីបន្ទាល់របស់គាត់ពីមុខស្ដេចនៅប្រទេសនោះ ។ ហេតុអ្វីបានជាពួកគេស្អប់គាត់ខ្លាំងម្ល៉េះ ? ពួកគេស្អប់ការអធិប្បាយរបស់គាត់ ជាពិសេសការបង្រៀនអំពីភាពចាំបាច់នៃការកែប្រែចិត្ត ! ពួកគេមិនបានជឿលើព្រះបន្ទូលនៃព្រះជាម្ចាស់នោះទេ ។

អ្នកដែលជឿលើព្រះបន្ទូលនៃព្រះទាំងអស់ ចាប់តាំងពីគ្រាដើមដំបូងនៃពិភពលោក ត្រូវគេធ្វើទុក្ខបុកម្នេញ ។ ពួកព្យាការីរបស់ព្រះជាច្រើនត្រូវគេសម្លាប់ ។ អ្នកជឿលើព្រះយេស៊ូវនៅជុំវិញពិភពលោក សូម្បីតែនៅសព្វថ្ងៃនេះក៏ដោយ ក៏ត្រូវបានគេវាយដំ ឃុំឃាំង ឬដាក់ទណ្ឌកម្មផងដែរ ។ ពួកគេជាច្រើនបានបាត់បង់ក្រុមគ្រួសារ ការងារ ឬមិត្តភក្ដិព្រោះតែពួកគេជឿ ហើយគោរពដើរតាមព្រះយេស៊ូវ ។ ព្រះគម្ពីរបរិសុទ្ធបានប្រាប់យើងច្បាស់លាស់ថា **អស់អ្នកដែលជឿលើព្រះយេស៊ូវ ហើយគោរពធ្វើតាមព្រះបន្ទូលរបស់ទ្រង់ នឹងទទួលរងនូវសេចក្ដីបៀតបៀន** ។

**ឯអស់អ្នកណាដែលចង់រស់ ដោយគោរពប្រតិបត្តិដល់ព្រះគ្រីស្ទយេស៊ូវ នោះនឹងត្រូវមានសេចក្ដីបៀតបៀនដែរ ។** (*២ធីម៉ូថេ ៣:១២*)

ព្រះយេស៊ូវបានជួបប្រទះនូវសេចក្ដីបៀតបៀនយ៉ាងច្រើន ខណៈពេលដែលទ្រង់បានគង់នៅលើផែនដីនេះ ។ មនុស្សជាច្រើនបានស្អប់ព្រះយេស៊ូវ ព្រោះទ្រង់បានប្រកាសថា ទ្រង់គឺជាព្រះរាជបុត្រានៃព្រះដែលបានយាងមកពីឋានសួគ៌ (សូមមើលព្រះគម្ពីរយ៉ូហាន ៦:៣៥-៥៩) ។ ពួកគេក៏បានស្អប់ទ្រង់ដែរ ព្រោះការបង្រៀនរបស់ទ្រង់ ។ ព្រះយេស៊ូវបានប្រាប់ដល់ប្រជាជនថា ពួកគេមិនអាចសង្គ្រោះខ្លួនឯងបានទេ បើពួកគេធ្វើតាមផ្លូវសាសនា ឬដោយការធ្វើទង្វើល្អនោះ (សូមមើលព្រះគម្ពីរម៉ាថាយ ៥:២០) ។ ពួកគេបានស្អប់ការបង្រៀនរបស់ទ្រង់ ហើយព្យាយាមបំផ្លាញទ្រង់ ។ នេះហើយជាមូលហេតុមួយដែលអ្នកដឹកនាំសាសនានៅសម័យនោះបានសម្លាប់ទ្រង់ ។ នៅពេលដែលពួកគេបានសម្លាប់ទ្រង់ ពួកគេមិនបានដឹងថា

ព្រះយេស៊ូវអនុញ្ញាតឲ្យពួកគេសម្លាប់ទ្រង់ ប្រយោជន៍ឲ្យទ្រង់អាចសងថ្លៃលោះបាបរបស់យើងគ្រប់ៗទេ ។ ពួកគេក៏មិនបានដឹងដែរថា បន្ទាប់ពីព្រះយេស៊ូវបានសុគត ហើយរស់ឡើងវិញ នោះនឹងមានមនុស្សរាប់លាននាក់ជឿ ហើយដើរតាមទ្រង់ផង ។ ព្រះយេស៊ូវជាគំរូរបស់យើងរាល់គ្នា ទ្រង់បានបង្រៀនយើងអំពីការលះបង់ និងសេចក្តីអំណរ ដើម្បីធ្វើជាសិស្សដ៏ពិតរបស់ព្រះយេស៊ូវ ។

## សេចក្តីបង្រៀនអំពីការលះបង់ ដើម្បីធ្វើជាសិស្សដ៏ពិតរបស់ព្រះយេស៊ូវ ៖

### ១. សេចក្តីបង្រៀនរបស់ព្រះយេស៊ូវ

ព្រះយេស៊ូវបានព្រមានហ្វូងមនុស្សថា មនុស្សទាំងឡាយណាដែលចង់ធ្វើជាសិស្សរបស់ទ្រង់ ត្រូវតែមានចិត្តលះបង់ជាមុនសិន ។

**ថ្ងៃមួយ មានមហាជនច្រើនកុះករធ្វើដំណើរទៅជាមួយព្រះអង្គ ។ ព្រះអង្គបែរព្រះភក្ត្រ ហើយមានព្រះបន្ទូលទៅគេថា ៖ «បើអ្នកណាមកតាមខ្ញុំ ហើយមិនបានលះអាល័យពីឪពុកម្តាយ ប្រពន្ធកូន បងប្អូនប្រុសស្រី និងជីវិតខ្លួនទេ អ្នកនោះមិនអាចធ្វើជាសិស្សរបស់ខ្ញុំបានឡើយ ។ អ្នកណាដែលមិនផ្ទុកឈើឆ្កាងរបស់ខ្លួន ហើយមកតាមខ្ញុំ អ្នកនោះក៏ពុំអាចធ្វើជាសិស្សរបស់ខ្ញុំបានដែរ ។ ដូច្នេះ ក្នុងចំណោមអ្នករាល់គ្នា បើអ្នកណាមិនលះបង់អ្វីៗទាំងអស់ដែលខ្លួនមានទេ នោះមិនអាចធ្វើជាសិស្សរបស់ខ្ញុំបានឡើយ»** (*លូកា ១៤:២៥-២៧, ៣៣ ដកស្រង់ចេញព្រះគម្ពីរកែសម្រួលឆ្នាំ ២០១៤*)

**ក. យើងត្រូវព្រមលះអាល័យពីមនុស្ស និងរបស់ទ្រព្យខ្លួនទាំងអស់ ដើម្បីធ្វើជាសិស្សដ៏ពិតរបស់ព្រះយេស៊ូវ** (លូកា ១៤:២៥-២៦, ៣៣)

តើខដ៏ចម្លែកនេះមានអត្ថន័យយ៉ាងដូចម្តេច ? តើព្រះយេស៊ូវចង់ឲ្យយើងធ្វើអំពើបាបដោយការស្អប់ឪពុកម្តាយ និងក្រុមគ្រួសាររបស់យើងមែនឬ ? តើទ្រង់ចង់ឲ្យយើងស្អប់ជីវិតរបស់យើងផ្ទាល់មែនឬ ? ព្រះយេស៊ូវកំពុងតែបង្រៀនយើងអំពីគោលការណ៍មួយដែលមានសារៈសំខាន់បំផុត ។ ពាក្យ «លះអាល័យ» ក្នុងខគម្ពីរនេះមិនមែនមានន័យថា ព្រះយេស៊ូវសព្វព្រះហឫទ័យឲ្យយើងឈប់ស្រឡាញ់ក្រុមគ្រួសាររបស់យើង ឬប្រឆាំងនឹងពួកគេនោះទេ ! ព្រះយេស៊ូវមានព្រះបន្ទូលបំផ្លើស ដើម្បីឲ្យយើងចាប់អារម្មណ៍ថា ត្រូវស្រឡាញ់ព្រះជាម្ចាស់ខ្លាំងបំផុត ។ បើប្រៀបធៀបការស្រឡាញ់របស់យើងចំពោះគ្រួសារ វត្ថុផ្សេងៗ និងជីវិតរបស់ខ្លួនឯង ទៅនឹងការស្រឡាញ់របស់យើងចំពោះព្រះជាម្ចាស់ ហាក់ដូចជាយើងបាន

លះបង់គ្រួសាររបស់យើងទៅវិញ ! ព្រះយេស៊ូវទ្រង់បានជ្រាបហើយថា យើងរាល់គ្នាស្រឡាញ់ក្រុមគ្រួសាររបស់យើងខ្លាំងណាស់ ។ យើងស្រឡាញ់ជីវិតរបស់យើង ហើយយើងមិនចង់ស្លាប់ទេ ។ ព្រះយេស៊ូវកំពុងតែប្រាប់យើងថា បើយើងចង់ធ្វើជាសិស្សដ៏ពិតរបស់ទ្រង់ នោះយើងត្រូវតែស្រឡាញ់ទ្រង់ច្រើនជាងអ្វីៗទាំងអស់ សូម្បីតែមនុស្សដែលយើងស្រឡាញ់ជាទីបំផុតក៏ដោយ ។

ខ. **យើងត្រូវព្រមផ្ទុកឈើឆ្កាងខ្លួន ដើម្បីធ្វើជាសិស្សដ៏ពិតរបស់ព្រះយេស៊ូវ** (លូកា ១៤:២៧)

ហេតុអ្វីបានជាព្រះយេស៊ូវបានប្រាប់ហ្វូងមនុស្សអំពីរឿងនេះ ? ពីព្រោះនៅពេលដែលយើងដើរតាមទ្រង់ឲ្យអស់ពីដួងចិត្ត ជួនកាលក្រុមគ្រួសាររបស់យើងនឹងស្អប់ ហើយប្រឆាំងនឹងយើង ។ នៅពេលដែលយើងគោរពតាមគ្រប់ព្រះបន្ទូលរបស់ទ្រង់ ការនោះអាចធ្វើឲ្យយើងបាត់បង់មិត្តភក្តិខ្លះ បាត់បង់ការងារ ឬខាតបង់នៅក្នុងមុខជំនួញរបស់យើងផងដែរ ។ អ្នកជឿលើព្រះយេស៊ូវខ្លះថែមទាំងបាត់បង់ទ្រព្យសម្បត្តិទាំងអស់ដែលពួកគេមាន ។ ការដែលយើងដើរតាមព្រះគ្រីស្ទអាចនាំឲ្យអ្នកដទៃបដិសេធយើង ហើយពេលខ្លះយើងត្រូវប្រឈមមុខនឹងសេចក្តីស្លាប់ថែមទៀតផង ។ ការលំបាកទាំងអស់នេះប្រៀបដូចជាការស្លាប់ដែលពោពេញទៅដោយការឈឺចាប់ និងភាពអាម៉ាស់មុខនៅលើឈើឆ្កាង ។ នោះហើយជាអត្ថន័យនៃព្រះបន្ទូលរបស់ព្រះយេស៊ូវទៅកាន់ហ្វូងមនុស្សថា យើងត្រូវតែ «ផ្ទុកឈើឆ្កាងរបស់ខ្លួន ហើយមកតាមខ្ញុំ» ។

តើលោកអ្នកដឹងទេថា ឥឡូវនេះ នៅក្នុងប្រទេសវៀតណាម មានអ្នកជឿលើព្រះយេស៊ូវជាច្រើន ត្រូវបានចាប់ដាក់គុក ព្រោះតែសេចក្តីជំនឿរបស់ពួកគេទៅលើព្រះយេស៊ូវ ។ ពួកគ្រីស្ទានជាច្រើនបានទទួលទណ្ឌកម្ម ហើយត្រូវបានសម្លាប់នៅក្នុងប្រទេសចិនក្នុងរយៈពេល១០០ឆ្នាំនេះ ។ នៅក្នុងប្រទេសខ្លះដែលកាន់សាសនាអ៊ីស្លាម មានប្រជាជនខ្លះត្រូវបានសម្លាប់ ហើយក្រុមគ្រួសាររបស់ពួកគេត្រូវបានរងនូវភាពអាម៉ាស់មុខដោយសារតែសេចក្តីជំនឿរបស់ពួកគេទៅលើព្រះយេស៊ូវ ។ ព្រះយេស៊ូវមានព្រះបន្ទូលប្រាប់យើងឲ្យដឹងមុនថា រឿងនេះពិតជាកើតមានឡើង ហើយទ្រង់បានរំឭកដល់យើងឲ្យពិចារណាអំពីការលះបង់មុនពេលដែលយើងក្លាយជាសិស្សរបស់ទ្រង់ ។ តើលោកអ្នកស្រឡាញ់អ្នកណាច្រើនជាងគេ គឺព្រះយេស៊ូវ ឬមនុស្សដទៃទៀត ? តើលោកអ្នកកោតខ្លាចអ្នកណាច្រើនជាងគេ គឺមនុស្ស ឬព្រះជាម្ចាស់ ? តើលោកអ្នកស្រឡាញ់ការងារ មុខជំនួញ ឬក៏ទ្រព្យសម្បត្តិរបស់ខ្លួនច្រើនជាងព្រះយេស៊ូវដែរឬទេ ?

នៅពេលនោះ ព្រះយេស៊ូវបានប្រទានឧទាហរណ៍២ ដើម្បីជួយយើងទាំងអស់គ្នាឲ្យយល់អំពីសារៈសំខាន់នៃរឿងនេះ ។

**ឧទាហរណ៍ទី១ ៖ អ្នកសង់ផ្ទះពីថ្ម**

ដ្បិតក្នុងពួកអ្នករាល់គ្នា បើមានអ្នកណាចង់សង់ផ្ទះពីថ្ម តើមិនអង្គុយលៃលកមើលជាមុនសិន ដើម្បីឲ្យដឹងថាមានល្មមនឹងធ្វើបង្ហើយបាន ឬមិនបានទេឬ ? ពុំនោះទេ ពេលចាក់គ្រឹះហើយ តែមិនអាចបង្ហើយបាន អស់អ្នកណាដែលឃើញគេនឹងសើចចំអកដោយពាក្យថា «អ្នកនេះបានចាប់ផ្ដើមសង់ផ្ទះ តែបង្ហើយមិនបាន» ។ (*លូកា ១៤:២៨-៣០ ដកស្រង់ចេញព្រះគម្ពីរកែសម្រួលឆ្នាំ ២០១៥*)

**ឧទាហរណ៍ទី២ ៖ ស្ដេចដែលទៅច្បាំងនឹងស្ដេចមួយទៀត**

ឬតើមានស្ដេចឯណា ដែលរៀបចេញទៅច្បាំងនឹងស្ដេចមួយទៀត ឥតអង្គុយពិគ្រោះមើលជាមុនសិន ដើម្បីឲ្យដឹងថា ខ្លួនអាចនាំពលមួយម៉ឺនទៅតទល់នឹងស្ដេច ដែលនាំពលពីរម៉ឺនមកច្បាំងបាន ឬមិនបាននោះ ? ប្រសិនបើឃើញថាមិនអាចតទល់បាននោះទ្រង់នឹងចាត់រាជទូតឲ្យទៅសុំចងស្ពានមេត្រីនឹងគ្នា ក្នុងកាលដែលស្ដេចមួយអង្គទៀតនៅឆ្ងាយនៅឡើយ ។ (*លូកា ១៤:៣១-៣២ ដកស្រង់ចេញព្រះគម្ពីរកែសម្រួលឆ្នាំ ២០១៥*)

ហេតុអ្វីបានជាព្រះយេស៊ូវលើកឧទាហរណ៍ទាំងពីរនេះឡើងមកមានបន្ទូលនៅបន្ទាប់ពីខ២៥-២៧ ? ពីព្រោះទ្រង់ចង់ឲ្យយើងគិតពិចារណាមុនអំពីការលះបង់ ដើម្បីធ្វើជាសិស្សដ៏ពិតរបស់ព្រះយេស៊ូវ ដូចជាអ្នកសង់ផ្ទះពីថ្ម និងស្ដេចដែលទៅច្បាំងនឹងស្ដេចមួយទៀតក៏បានគិតពិចារណាមុនយ៉ាងនោះដែរ ។ ផ្លូវរបស់ព្រះយេស៊ូវគឺត្រង់ ហើយចង្អៀត មិនងាយស្រួលទេ ។ មនុស្សជាច្រើននឹងជ្រើសរើសស្រឡាញ់ជីវិត និងទ្រព្យសម្បត្តិរបស់ពួកគេ ឬមនុស្សដទៃទៀតច្រើនជាងជ្រើសយកព្រះយេស៊ូវ ។ មនុស្សជាច្រើននឹងជ្រើសរើសយករបស់ទាំងអស់នេះ ហើយគិតថា វាសំខាន់ជាងការទទួលនូវការអត់ទោសបាប និងជីវិតដ៏នៅអស់កល្បជានិច្ចនៅក្នុងព្រះយេស៊ូវគ្រីស្ទ ។

### ២. សេចក្តីបង្រៀនរបស់សាវកពេត្រុស

សិស្សម្នាក់ក្នុងបណ្តាសិស្សរបស់ព្រះយេស៊ូវ គឺសាវកពេត្រុសបានពន្យល់ពីមូលហេតុដែលអ្នកជឿលើព្រះយេស៊ូវធ្វើឲ្យពួកអ្នកមិនជឿអាក់អន់ចិត្ត ។ លោកមានប្រសាសន៍ថា ៖

> ដូច្នេះ ដែលព្រះគ្រីស្ទទ្រង់បានរងទុក្ខក្នុងសាច់ឈាមជំនួសយើងរួចហើយ នោះត្រូវឲ្យអ្នករាល់គ្នាមានគំនិតដូច្នោះដែរ ទុកជាគ្រឿងការពារខ្លួន ដ្បិតអ្នកណាដែលបានរងទុក្ខក្នុងសាច់ឈាម នោះបានឈប់ខាងឯអំពើបាបហើយ ដើម្បីកុំឲ្យបង់ពេលដែលសល់ និងរស់នៅខាងសាច់ឈាម តាមតែសេចក្តីប៉ងប្រាថ្នារបស់មនុស្សទៀតឡើយ គឺតាមបំណងព្រះហឫទ័យនៃព្រះវិញ ។ ដ្បិតដែលពីដើម យើងរាល់គ្នាបានធ្វើតាមបំណងចិត្តរបស់សាសន៍ដទៃ ទាំងដើរក្នុងសេចក្តីអាសអាភាស ការស្រើបស្រាល ការចំណូលស្រា ស៊ីផឹកជ្រុល ការប្រមឹក និងការថ្វាយបង្គំរូបព្រះដែលសុទ្ធតែខុសច្បាប់ នោះល្មមដល់យើងហើយ ។ គេក៏ឆ្ងល់ ដែលអ្នករាល់គ្នាមិនរត់ទៅ តាមសេចក្តីខូចអាក្រក់ដ៏ហូរហៀរ ជាមួយនឹងគេដែរ បានជាគេប្រមាថដល់អ្នករាល់គ្នា ។
> (*១ពេត្រុស ៤:១-៤*)

មនុស្សជាច្រើននឹងមិនយល់ពីយើង (អ្នកជឿលើព្រះយេស៊ូវ) ហើយមិនយល់ពីមូលហេតុដែលជីវិតយើងមានការផ្លាស់ប្តូរយ៉ាងខ្លាំងដូច្នេះឡើយ ។ ពួកគេនឹងមិនយល់ពីសេចក្តីជំនឿរបស់យើង ហើយមិនយល់ពីមូលហេតុដែលព្រះបន្ទូលនៃព្រះមានសារៈសំខាន់សម្រាប់យើងនោះទេ ។ ការទាំងអស់នេះអាចធ្វើឲ្យអ្នកមិនជឿអាក់អន់ចិត្តដល់អ្នកជឿ ។ មនុស្សជាច្រើននឹងចំអកចំអន់ឲ្យយើង ព្រោះតែយើងមិនព្រមធ្វើតាមទង្វើនៃអំពើបាបរបស់ពួកគេ ។

ដូចជាព្រះយេស៊ូវបានបង្រៀនហ្វូងមនុស្សអំពីភាពចាំបាច់នៃការលះបង់ ដើម្បីធ្វើជាសិស្សដ៏ពិតរបស់ទ្រង់ ទ្រង់ក៏បានលើកទឹកចិត្តសិស្សពិតប្រាកដរបស់ព្រះអង្គដោយបានបង្រៀនពួកគេអំពីសេចក្តីអំណរនៃការក្លាយជាសិស្សដ៏ពិតរបស់ទ្រង់យ៉ាងនោះដែរ ។

## សេចក្តីបង្រៀនអំពីសេចក្តីអំណរ ដើម្បីធ្វើជាសិស្សដ៏ពិតរបស់ព្រះយេស៊ូវ ៖

### ១. សេចក្តីបង្រៀនរបស់ព្រះយេស៊ូវ

ព្រះយេស៊ូវបានប្រាប់ហ្វូងមនុស្សថា មនុស្សទាំងឡាយណាដែលធ្វើជាសិស្សរបស់ទ្រង់ នឹង

ទទួលព្រះពរ និងរង្វាន់ដ៏ធំនៅឋានសួគ៌ ។

> មានពរហើយ អស់អ្នកដែលត្រូវគេបៀតបៀន ដោយព្រោះសេចក្តីសុចរិត ដ្បិតនគរស្ថានសួគ៌ជារបស់ផងអ្នកទាំងនោះ ។ អ្នករាល់គ្នាមានពរ ក្នុងកាលដែលគេជេរ បៀតបៀន ហើយនិយាយបង្ខុសគ្រប់ទាំងសេចក្តីអាក្រក់ ពីអ្នករាល់គ្នា ដោយព្រោះខ្ញុំ ។ ចូរមានចិត្តអំណរ ហើយរីករាយជាខ្លាំងចុះ ដ្បិតអ្នករាល់គ្នាមានរង្វាន់ជាធំនៅឯស្ថានសួគ៌ ពីព្រោះគេក៏បានធ្វើទុក្ខដល់ពួកហោរា ដែលនៅមុនអ្នករាល់គ្នា បែបដូច្នោះដែរ ។ (*ម៉ាថាយ ៥:១០-១២*)

> មានពរហើយ កាលណាមនុស្សនឹងស្អប់អ្នករាល់គ្នា ព្រមទាំងកាត់កាល់ ត្មះតិះដៀល ហើយចោលឈ្មោះអ្នករាល់គ្នាចេញ ទុកដូចជាអាក្រក់ ដោយព្រោះកូនមនុស្ស ។ ចូរអ្នករាល់គ្នាអរសប្បាយឡើងនៅថ្ងៃនោះ ហើយលោតកញ្ឆេងចុះ ដ្បិតមើល អ្នករាល់គ្នាមានរង្វាន់ជាយ៉ាងធំ នៅឯស្ថានសួគ៌ ឯពួកឰយុកោរបស់គេ ក៏បានប្រព្រឹត្តចំពោះពួកហោរាពីដើមយ៉ាងដូច្នោះដែរ ។ (*លូកា ៦:២២-២៣*)

តើខគម្ពីរទាំងពីរដ៏ចម្លែកនេះមានអត្ថន័យយ៉ាងដូចម្តេច ? ជាធម្មតា យើងមិនបានគិតថា ការបៀតបៀនជាទង្វើអ្វីមួយដែលគួរឲ្យរីករាយនោះទេ ។ នៅក្នុងខគម្ពីរទាំងពីរនេះ ព្រះយេស៊ូវបានសន្យាថា ទ្រង់នឹងប្រទានពរដ៏បរិបូរដល់មនុស្សទាំងអស់ដែលស៊ូទ្រាំក្នុងការបៀតបៀនព្រោះតែសេចក្តីជំនឿរបស់ពួកគេចំពោះទ្រង់ ។ ហេតុអ្វីបានជាព្រះយេស៊ូវប្រទានការសន្យានេះដល់ហ្វូងមនុស្ស ? ព្រះអង្គបានប្រទានការសន្យានេះ ដើម្បីលើកទឹកចិត្តសិស្សពិតប្រាកដរបស់ទ្រង់ឲ្យតស៊ូដល់ទីបំផុត ។ យើងត្រូវតែរីករាយនៅក្នុងការរងទុក្ខរបស់យើង ហើយចងចាំពីការរងទុក្ខដែលព្រះយេស៊ូវគ្រីស្ទបានទទួលជំនួសយើងនៅលើឈើឆ្កាង ។

## ២. សេចក្តីបង្រៀនរបស់សាវកពេត្រុស

ដូចជាសាវកពេត្រុសបានបង្រៀនអំពីការលះបង់ និងពីមូលហេតុដែលពួកអ្នកមិនជឿអាក់អន់ចិត្តចំពោះអ្នកជឿ លោកក៏បានលើកទឹកចិត្តសិស្សរបស់ព្រះយេស៊ូវឲ្យសរសើរតម្កើងដល់ព្រះ ហើយទុកចិត្តព្រះទាំងស្រុងក្នុងកាលដែលពួកគេទទួលនូវការបៀតបៀនយ៉ាងនោះដែរ ។ លោកមានប្រសាសន៍ថា ៖

ពួកស្ងួនភ្ងាអើយ កុំឲ្យមានប្លែកក្នុងចិត្ត ដោយភ្លើងដ៏ក្តៅក្រហាយ ដែលកំពុងតែល្បង អ្នករាល់គ្នា ទុកដូចជាកើតមានសេចក្តីចំឡែកនោះឡើយ ។ ត្រូវអរសប្បាយវិញ ដោយព្រោះមានចំណែកក្នុងការរងទុក្ខរបស់ព្រះគ្រីស្ទ ដើម្បីឲ្យអ្នករាល់គ្នាបាន ត្រេកអរវីករាយជាខ្លាំង ក្នុងកាលដែលសិរីល្អទ្រង់លេចមក ។ បើសិនជាគេតិះដៀល អ្នករាល់គ្នា ដោយព្រោះព្រះគ្រីស្ទ នោះមានពរហើយ ពីព្រោះព្រះវិញ្ញាណដ៏មាន សិរីល្អ គឺជាព្រះវិញ្ញាណនៃព្រះ ទ្រង់សណ្ឋិតលើអ្នករាល់គ្នាហើយ ។ កុំបីឲ្យ អ្នករាល់គ្នាណាមួយរងទុក្ខទោស ដោយព្រោះសម្លាប់គេ ឬលួចគេ ឬធ្វើការអាក្រក់ ឬ សៀតចូលក្នុងការរបស់អ្នកដទៃឡើយ ។ តែបើរងទុក្ខ ដោយព្រោះជាពួកគ្រីស្ទានវិញ នោះកុំឲ្យខ្មាសឲ្យសោះ ចូរសរសើរតំកើងដល់ព្រះ ដោយព្រោះនាមនោះវិញ ។ ដូច្នេះ ពួកអ្នកដែលរងទុក្ខតាមព្រះហឫទ័យនៃព្រះ នោះត្រូវផ្ញើព្រលឹងខ្លួនទុកនឹងព្រះ ដ៏បង្កបង្កើត ដែលទ្រង់ស្មោះត្រង់ ដោយខ្លួនប្រព្រឹត្តការល្អចុះ ។ (*១ពេត្រុស ៤:១២-១៦, ១៩*)

យើងនឹងទទួលបានព្រះពរ នៅពេលដែលយើងបានទទួលនូវការបៀតបៀនដោយសារតែ ការជឿលើព្រះគ្រីស្ទ ។ យើងគួរតែមានចិត្តរីករាយ នៅពេលដែលមានការបៀតបៀននោះ ព្រោះការ នេះបានប្រាប់យើងថា ព្រះវិញ្ញាណបរិសុទ្ធនៃព្រះសណ្ឋិតនៅក្នុងយើង ។ នៅក្នុងគ្រាដែលមានការ បៀតបៀនទាំងនេះ យើងត្រូវតែទុកចិត្តលើសេចក្តីស្មោះត្រង់របស់ព្រះ ហើយជឿជាក់លើការសន្យា របស់ទ្រង់ថា ទ្រង់នឹងផ្តល់សេចក្តីយុត្តិធម៌នៅថ្ងៃជំនុំជម្រះ ។ ដូច្នេះ យើងត្រូវតែទុកចិត្តលើព្រះ ។

## សំណួរមេរៀនទី៤ ៖

១. នៅពេលដែលសាវកប៉ុលបានអធិប្បាយ ហើយបង្រៀនដល់សាសន៍យូដាជាច្រើន តើគាត់ទទួល បានការឆ្លើយតបបែបណាពីពួកគេ ?

២. ហេតុអ្វីបានជាពួកគេស្អប់សាវកប៉ុលខ្លាំងម្ល៉េះ ?

៣. តើអ្នកជឿលើព្រះយេស៊ូវទាំងអស់ប្រឈមមុខនឹងការបៀតបៀនដែរឬទេ ?

៤. យោងតាមលូកា ១៤:២៥-២៧ តើព្រះយេស៊ូវបានបង្រៀនយើងអំពីអ្វីខ្លះ ដែលយើងត្រូវតែព្រមធ្វើ ដើម្បីធ្វើជាសិស្សដ៏ពិតរបស់ព្រះយេស៊ូវ ? (តម្រុយ ៖ មាន២យ៉ាង)

៥. តើការលះអាល័យពីឪពុកម្ដាយ បងប្អូនប្រុសស្រី ប្ដីប្រពន្ធ និងកូនចៅ ដើម្បីដើរតាមព្រះយេស៊ូវ មានអត្ថន័យយ៉ាងដូចម្ដេចខ្លះ ?

៦. តើការផ្ទុកឈើឆ្កាងរបស់យើងមានអត្ថន័យយ៉ាងដូចម្ដេចខ្លះ ?

៧. តើឧទាហរណ៍ទាំងពីរ ដែលព្រះយេស៊ូវបានលើកឡើងបន្ទាប់ពីសេចក្ដីបង្រៀនរបស់ទ្រង់នៅក្នុងលូកា ១៤:២៥-២៧ មានអ្វីខ្លះ ?

៨. ហេតុអ្វីបានជាព្រះយេស៊ូវលើកយកឧទាហរណ៍ទាំងពីរមកប្រើបន្ទាប់ពីសេចក្ដីបង្រៀនរបស់ទ្រង់ ?

៩. យោងតាម១ពេត្រុស ៤:១-៤ តើអ្វីជាមូលហេតុដែលអ្នកមិនជឿចំអកចំអន់ឲ្យអ្នកជឿលើព្រះយេស៊ូវ ?

១០. យោងតាមម៉ាថាយ ៥:១០-១២ និងលូកា ៦:២២-២៣ តើអ្នកជឿលើព្រះយេស៊ូវគួរតែមានឥរិយាបថបែបណាចំពោះការបៀតបៀន ?

១១. តើព្រះយេស៊ូវបានសន្យាប្រទានអ្វីខ្លះចំពោះអ្នកដែលបានទទួលនូវសេចក្ដីបៀតបៀនដោយព្រោះព្រះនាមព្រះអង្គ ?

១២. យោងតាម១ពេត្រុស ៤:១២-១៦,១៩ តើអ្នកជឿលើព្រះយេស៊ូវត្រូវធ្វើអ្វីខ្លះ នៅពេលដែលមានអ្នកមិនជឿមកបៀតបៀន ?

# មេរៀនទី៥

## សំណួរទី៥ ៖ តើពិធីជ្រមុជទឹកមានន័យយ៉ាងដូចម្ដេច ?

នៅក្នុងសៀវភៅនេះ យើងបានលើកឡើងទីបន្ទាល់របស់សាវកប៉ុលក្នុងព្រះគម្ពីរកិច្ចការ ២៦:១៦-២១ ជាគោល ។ យើងបានរៀនអំពីបេសកកម្មរបស់លោកប៉ុលដែលព្រះយេស៊ូវបានប្រទានឲ្យគាត់នៅក្នុងខ១៦-១៨ ហើយបានមើលគំរូរបស់លោកក្នុងខ១៩-២១ ។ តាមរយៈបេសកកម្ម និងគំរូរបស់លោក យើងបានសិក្សាពីមូលដ្ឋានគ្រឹះនៃសេចក្ដីជំនឿដ៏ពិត (មេរៀនទី១-២) ហើយនិងការកែប្រែចិត្តដ៏ពិត (មេរៀនទី៣-៤) ។ បន្ទាប់ពីមនុស្សម្នាក់បានកែប្រែចិត្តពីអំពើបាបរបស់ខ្លួន ហើយបានជឿលើព្រះយេស៊ូវពិតប្រាកដនោះ តើសាវកប៉ុលបានណែនាំសិស្សថ្មីទាំងអស់នោះឲ្យទទួលអ្វី ? អ្នកទាំងអស់បានទទួលពិធីជ្រមុជទឹក (សូមមើលព្រះគម្ពីរកិច្ចការ ១៦:១៤-១៥, ៣០-៣៣) ។

នៅក្នុងមេរៀនចុងក្រោយនេះ យើងត្រូវរៀនពីសកម្មភាពមួយទៀត ដែលមានសារៈសំខាន់ខ្លាំងណាស់ គឺពិធីជ្រមុជទឹក ។ នៅពេលដែលយើងមើលព្រះបន្ទូលនៃព្រះយេស៊ូវ យើងឃើញច្បាស់ថា ពួកអ្នកជឿលើព្រះយេស៊ូវនៅជំនាន់មុនសុទ្ធតែទទួលពិធីជ្រមុជទឹកនៅក្នុងទន្លេទាំងអស់គ្នា ។ តើអ្វីជាពិធីជ្រមុជទឹក ? ហេតុអ្វីបានជាយើងត្រូវទទួលពិធីជ្រមុជទឹកនោះ ? តើនរណាខ្លះត្រូវទទួលពិធីជ្រមុជទឹក ? យើងនឹងឆ្លើយសំណួរទាំងអស់នេះដូចខាងក្រោម ។

### បទបញ្ញត្តិនៃពិធីជ្រមុជទឹក

មុនពេលដែលព្រះយេស៊ូវយាងទៅកាន់ឋានសួគ៌វិញ ទ្រង់បានប្រទានបទបញ្ញត្តិដ៏សំខាន់មួយទៅកាន់ពួកសិស្សរបស់ព្រះអង្គ ។

> **ដូច្នេះ ចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធចុះ** (*ម៉ាថាយ ២៨:១៩*)

អស់អ្នកដែលក្លាយជាសិស្សដ៏ពិតរបស់ព្រះយេស៊ូវត្រូវតែទទួលពិធីជ្រមុជទឹក ។ ពិធីជ្រមុជទឹកមានសារៈសំខាន់ណាស់ចំពោះព្រះ និងជាជំហានដំបូងមួយនៃការប្រតិបត្តិរបស់គ្រីស្ទានថ្មី ។ ពិធីជ្រមុជទឹក គឺសម្រាប់តែអ្នកណាដែលសម្រេចចិត្តធ្វើជាសិស្សដ៏ពិតប្រាកដរបស់ព្រះយេស៊ូវគ្រីស្ទតែប៉ុណ្ណោះ ។

# អត្ថន័យនៃពិធីជ្រមុជទឹក

មុនពេលដែលយើងគិតពិចារណាលើអត្ថន័យនៃពិធីជ្រមុជទឹក យើងត្រូវតែគិតអំពីអ្វីដែលមិនមែនជាអត្ថន័យនៃពិធីជ្រមុជទឹកជាមុនសិន ។ តើអ្វីដែលមិនមែនជាអត្ថន័យពិតនៃពិធីជ្រមុជទឹក ?

១. ពិធីជ្រមុជទឹកមិនមែនជាពិធីសាសនាមួយដែលយើងត្រូវធ្វើ ដើម្បីទទួលបានសំណាងល្អសម្រាប់ក្រុមគ្រួសារ ឬមុខជំនួញរបស់យើងនោះទេ ។

២. ពិធីជ្រមុជទឹកមិនមែនជាវិធីមួយ ដើម្បីសម្អាតអំពើបាបរបស់យើងនោះទេ ។ មានតែព្រះលោហិតនៃព្រះយេស៊ូវប៉ុណ្ណោះ ដែលមានអំណាចព្រះចេស្តាសម្អាតអំពើបាបរបស់យើងបាន ។

៣. ពិធីជ្រមុជទឹកមិនមែនជាផ្នែកសំខាន់អ្វីមួយនៃសេចក្តីសង្គ្រោះ ដែលនាំឲ្យយើងរួចពីអំពើបាបនោះទេ ។ សេចក្តីសង្គ្រោះគឺជាអំណោយទាននៃព្រះ ដែលមកពីការសងថ្លៃលោះបាបរបស់ព្រះយេស៊ូវនៅលើឈើឆ្កាង ។ យើងទទួលសេចក្តីសង្គ្រោះដោយសារព្រះគុណ តាមរយៈសេចក្តីជំនឿ គឺមិនមែនអាងលើការប្រព្រឹត្តិល្អរបស់យើងនោះឡើយ ។

**ដ្បិតគឺព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារសេចក្តីជំនឿ ហើយសេចក្តីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ ក៏មិនមែនដោយការប្រព្រឹត្តិដែរ ក្រែងអ្នកណាអួតខ្លួន ។** (*អេភេសូរ ២:៨-៩*)

បើសិនពិធីជ្រមុជទឹកមិនមែនជាអ្វីៗដែលបានរៀបរាប់នៅខាងលើនេះទេ ដូច្នេះ តើពិធីជ្រមុជទឹកគឺជាអ្វី ?

**ក. ពិធីជ្រមុជទឹកជាទីបន្ទាល់នៃសេចក្តីសង្គ្រោះរបស់យើងក្នុងព្រះគ្រីស្ទ**

យើងទទួលពិធីជ្រមុជទឹក ដើម្បីបង្ហាញដល់អ្នកជឿលើព្រះយេស៊ូវឯទៀតៗថា យើងមានសេចក្តីជំនឿក្នុងព្រះយេស៊ូវ ហើយយើងចង់ដើរតាមព្រះអង្គដូចពួកគេដែរ ។ ម្យ៉ាងទៀត យើងទទួលពិធីជ្រមុជទឹក ដើម្បីបង្ហាញដល់អ្នកមិនទាន់ជឿលើព្រះយេស៊ូវថា យើងបានបែរចេញពីផ្លូវចាស់របស់យើង ដើម្បីដើរតាមព្រះយេស៊ូវ ។ បើសិនជាមានមនុស្សម្នាក់អះអាងថា ខ្លួនបានជឿលើព្រះយេស៊ូវរួចហើយ តែគាត់មិនព្រមទទួលពិធីជ្រមុជទឹក ដោយសារគាត់ខ្លាចអ្នកឯទៀតបៀតបៀនគាត់ អ្នកនោះមិនទាន់មានជំនឿពិតប្រាកដទៅលើព្រះយេស៊ូវនោះទេ ។ ដ្បិតព្រះយេស៊ូវមានព្រះបន្ទូលថា ៖

**ដូច្នេះ អស់អ្នកណាដែលទទួលថ្លែងប្រាប់ពីខ្ញុំ នៅមុខមនុស្សលោក នោះខ្ញុំនឹងទទួលថ្លែងប្រាប់ពីអ្នកនោះ នៅចំពោះព្រះវរបិតាខ្ញុំ ដែលគង់នៅស្ថានសួគ៌ដែរ ។ តែអ្នក**

ណាដែលមិនព្រមទទួលស្គាល់ខ្ញុំ នៅមុខមនុស្សលោកទេ នោះខ្ញុំក៏មិនព្រមទទួលស្គាល់អ្នកនោះ នៅចំពោះព្រះវរបិតាខ្ញុំ ដែលគង់នៅស្ថានសួគ៌ដែរ ។ (*ម៉ាថាយ ១០:៣២-៣៣*)

## ខ. ពិធីជ្រមុជទឹកជាទីសម្គាល់នៃអ្វីៗដែលបានកើតឡើងចំពោះយើងខាងវិញ្ញាណ

នៅពេលយើងទទួលពិធីជ្រមុជទឹក មានទីសម្គាល់៣យ៉ាង ដែលបញ្ជាក់ពីអ្វីដែលបានកើតឡើងចំពោះអ្នកជឿខាងវិញ្ញាណគឺ ៖

១. ពេលយើងឈរនៅក្នុងទឹក នោះជានិមិត្តរូបពីការរស់ក្នុងជីវិតចាស់ និងផ្លូវចាស់របស់យើង ។

២. ពេលយើងជ្រមុជនៅក្នុងទឹក នោះជានិមិត្តរូបពីការស្លាប់ខាងជីវិតចាស់ និងផ្លូវចាស់របស់យើង ។

៣. ពេលយើងងើបពីទឹកវិញ នោះជានិមិត្តរូបពីការរស់ឡើងវិញជាមួយព្រះយេស៊ូវ ដោយព្រះបានប្រទានឲ្យយើងបានជីវិតថ្មីក្នុងព្រះយេស៊ូវគ្រីស្ទ ។

តើអ្នករាល់គ្នាមិនដឹងទេឬអីថា យើងទាំងប៉ុន្មានដែលបានទទួលបុណ្យជ្រមុជក្នុងព្រះយេស៊ូវគ្រីស្ទ នោះគឺបានទទួលជ្រមុជក្នុងសេចក្ដីសុគតនៃទ្រង់ដែរ ? ដូច្នេះ យើងបានត្រូវកប់ជាមួយនឹងទ្រង់ហើយ ដោយទទួលជ្រមុជក្នុងសេចក្ដីស្លាប់ ដើម្បីឲ្យយើងបានដើរក្នុងជីវិតបែបថ្មី ដូចជាព្រះគ្រីស្ទបានរស់ពីស្លាប់ឡើងវិញ ដោយសារសិរីល្អនៃព្រះវរបិតាដែរ ។ ដ្បិតបើយើងបានជាប់ជាមួយនឹងទ្រង់ ក្នុងការដែលជាគំរូពីសេចក្ដីសុគតរបស់ទ្រង់ នោះក៏នឹងបានជាប់ក្នុងសេចក្ដីរស់ឡើងវិញរបស់ទ្រង់ដែរ ។ ដោយដឹងសេចក្ដីនេះថា មនុស្សចាស់របស់យើង បានត្រូវឆ្កាងជាមួយនឹងទ្រង់ហើយ ដើម្បីឲ្យតួអំពើបាបបានត្រូវសូន្យទៅ ប្រយោជន៍កុំឲ្យយើងនៅបំរើអំពើបាបទៀតឡើយ ។ ដ្បិតអ្នកណាដែលស្លាប់ នោះក៏បានរាប់ជាសុចរិតរួចពីបាបហើយ ។ (*រ៉ូម ៦:៣-៧*)

**ចំណាំពិសេស** ៖ នៅក្នុងករណីដែលលោកអ្នកបានទទួលពិធីជ្រមុជទឹកជាច្រើនឆ្នាំកន្លងមក ប៉ុន្តែនៅពេលនោះ លោកអ្នកមិនបានជឿលើព្រះយេស៊ូវតាមគោលបំណងត្រឹមត្រូវនោះទេ (សូមមើលមេរៀនទី១ក្នុងសៀវភៅនេះ) លោកអ្នកគួរតែទទួលពិធីជ្រមុជទឹកជាថ្មីម្ដងទៀត ។

**គ. ពិធីជ្រមុជទឹកជាការសម្រេចចិត្តចូលជាសមាជិកនៅក្នុងក្រុមជំនុំតាមតំបន់មួយ**

នៅពេលយើងទទួលពិធីជ្រមុជទឹករួច យើងនឹងក្លាយជាសមាជិកនៅក្នុងក្រុមជំនុំតាមតំបន់មួយដែលយើងរស់នៅ ។ ក្រុមជំនុំតាមតំបន់ជាផ្នែកមួយនៃមរតករបស់យើង ដែលព្រះជាម្ចាស់បានបង្កើតឡើង ដើម្បីជួយយើងឲ្យរីកចម្រើនខាងវិញ្ញាណ ។ អ្នកជឿលើព្រះយេស៊ូវទាំងអស់គួរតែចូលជាសមាជិកនៅក្នុងក្រុមជំនុំតាមតំបន់មួយ ដែលគាត់រស់នៅ ។ តើអ្វីជាអត្ថន័យនៃក្រុមជំនុំរបស់ព្រះយេស៊ូវ ? តើអ្វីជាគោលបំណងនៃព្រះសម្រាប់ក្រុមជំនុំ ? តើអ្វីជាសកម្មភាពចាំបាច់នៃក្រុមជំនុំ ? នៅក្នុងសៀវភៅ *សំណួរនិងចម្លើយភាគទី២* យើងនឹងរៀនអំពីក្រុមជំនុំរបស់ព្រះយេស៊ូវគ្រីស្ទ ។

## សំណួរមេរៀនទី៥ ៖

១. តើនរណាបានបង្គាប់ឲ្យអ្នកជឿទាំងអស់ទទួលពិធីជ្រមុជទឹក ?

២. យោងតាមមេរៀនរបស់យើង តើអ្វីដែលមិនមែនជាអត្ថន័យពិតនៃពិធីជ្រមុជទឹក ? (តម្រុយ ៖ មាន៣យ៉ាង)

៣. យោងតាមមេរៀនរបស់យើង តើអត្ថន័យនៃពិធីជ្រមុជទឹកមានអ្វីខ្លះ ? (តម្រុយ ៖ មាន៣យ៉ាង)

៤. យោងតាមមេរៀនរបស់យើង តើពិធីជ្រមុជទឹកមានទីសម្គាល់អ្វីខ្លះ ? (តម្រុយ ៖ មាន៣យ៉ាង)

៥. តើយើងក្លាយទៅជាអ្វី នៅពេលដែលយើងបានទទួលពិធីជ្រមុជទឹករួច ?

# ចម្លើយនៃសំណួរមេរៀនផ្សេងៗ

## សំណួរមេរៀនទី១ ៖

១. យោងតាមមេរៀននេះ តើមានគោលបំណងមិនត្រឹមត្រូវអ្វីខ្លះ ដែលនាំឲ្យមនុស្សខ្លះអះអាងថា ខ្លួនបានជឿលើព្រះយេស៊ូវ ? (តម្រុយ ៖ មាន៦យ៉ាង)

*ក. ដើម្បីទទួលផលប្រយោជន៍ខាងសម្ភារៈ*

*ខ. ដើម្បីទទួលផលប្រយោជន៍ខាងចំណេះដឹង*

*គ. ព្រោះពួកគេគិតថា ជំនឿជឿលើព្រះយេស៊ូវមានអំណាច (ឬបារមី) ខ្លាំងជាងផ្លូវសាសនាចាស់របស់ខ្លួន*

*ឃ. ព្រោះពួកគេគិតថា ជំនឿជឿលើព្រះយេស៊ូវសប្បាយជាងផ្លូវសាសនាចាស់របស់ខ្លួន*

*ង. ព្រោះពួកគេគិតថា ជំនឿជឿលើព្រះយេស៊ូវងាយស្រួលជាងផ្លូវសាសនាចាស់របស់ខ្លួន*

*ច. ព្រោះពួកគេគិតថា ជំនឿជឿលើព្រះយេស៊ូវជាជំនឿរបស់ដូនតារបស់ខ្លួន*

២. តើអ្វីជាគោលបំណងត្រឹមត្រូវក្នុងការជឿលើព្រះយេស៊ូវ ?

*មនុស្សទាំងអស់នៅលើផែនដីនេះត្រូវតែជឿលើព្រះយេស៊ូវ ពីព្រោះមនុស្សគ្រប់គ្នាបានដាច់ចេញពីព្រះអាទិកររបស់ខ្លួន (ព្រះដែលបានបង្កើតអ្វីៗទាំងអស់) ដោយសារអំពើបាបនៅក្នុងពួកគេ ហើយពួកគេត្រូវផ្សះផ្សាជាមួយនឹងព្រះជាម្ចាស់វិញ ។ បើសិនជាមនុស្សយើងមិនបានផ្សះផ្សាជាមួយនឹងព្រះអាទិកររបស់ខ្លួន នោះមនុស្សយើងត្រូវទទួលទណ្ឌកម្មនៅឋាននរកអស់កល្បជានិច្ច ។*

៣. យោងតាមព្រះគម្ពីរកិច្ចការ ២៦:១៦-១៨ តើមានរូបភាពអ្វីខ្លះដែលសម្ដែងយ៉ាងច្បាស់លាស់អំពីស្ថានភាពរបស់មនុស្សយើងចំពោះព្រះជាម្ចាស់ ? (តម្រុយ ៖ មាន២យ៉ាង)

*ក. មនុស្សយើងជាអ្នកខ្វាក់ខាងវិញ្ញាណ ហើយត្រូវបែរចេញពីភាពងងឹត មកឯពន្លឺវិញ*

*ខ. មនុស្សយើងជាទាសករខាងវិញ្ញាណ ហើយត្រូវបែរចេញពីអំណាចអារក្សសាតាំង មកឯព្រះវិញ*

៤. មុនពេលមនុស្សម្នាក់ជឿលើព្រះយេស៊ូវ តើអ្នកនោះស្ថិតនៅក្រោមអំណាច និងការត្រួតត្រារបស់អ្នកណា ?

*មនុស្សយើងស្ថិតនៅក្រោមអំណាច និងការត្រួតត្រារបស់អារក្សសាតាំង ជាខ្មាំងសត្រូវធំរបស់ព្រះជាម្ចាស់*

៥. តើមនុស្សយើងអាចបានសង្គ្រោះពីអំណាចនៃសេចក្ដីងងឹតខាងវិញ្ញាណ និងពីអំណាចអារក្សសាតាំងបានដែរឬទេ ?

*មនុស្សយើងអាចសង្គ្រោះបាន តាមរយៈដំណឹងល្អនៃព្រះយេស៊ូវ !*

## សំណួរមេរៀនទី២ ៖

១. តើសេចក្ដីសន្យាទី១ ដែលព្រះយេស៊ូវបានសន្យាចំពោះអ្នកជឿលើទ្រង់ គឺជាអ្វី ?

*ព្រះយេស៊ូវនឹងអត់ទោសអំពើបាបឲ្យយើង*

២. យោងតាមមេរៀននេះ ហេតុអ្វីបានជាយើងត្រូវការរួចពីបាប ? (តម្រុយ ៖ មាន៣យ៉ាង)

*ក. ពីព្រោះយើងមិនបានគោរពព្រះជាម្ចាស់ឲ្យសមនឹងឋានៈព្រះអង្គ*

*ខ. ពីព្រោះយើងមិនបានស្ដាប់បង្គាប់ព្រះជាម្ចាស់*

*គ. ពីព្រោះយើងមានចិត្តអាត្មានិយម និងអំនួតចំពោះព្រះ និងអ្នកដទៃ*

៣. ហេតុអ្វីបានជាព្រះជាម្ចាស់មិនអាចមើលរំលងនូវអំពើបាបរបស់យើង ?

*ដោយសារព្រះជាម្ចាស់មានលក្ខណៈល្អបរិសុទ្ធ និងយុត្តិធម៌*

៤. តើយើងនឹងត្រូវការពេលយូរប៉ុណ្ណាទៅ ដើម្បីសងថ្លៃលោះបាបរបស់យើងឲ្យរួច ?

*អស់កល្បជានិច្ច*

៥. បើយើងចង់ត្រឡប់ជាសុចរិតដោយការប្រព្រឹត្តិរបស់ខ្លួនយើង តើយើងរាល់គ្នាត្រូវកាន់តាមក្រឹត្យវិន័យរបស់ព្រះប៉ុន្មានបទ ?

*យើងត្រូវកាន់តាមក្រឹត្យវិន័យរបស់ព្រះទាំងមូលពេញមួយជីវិត ហើយក៏ត្រូវកើតមកពីមាតាបិតាដែលគ្មានអំពើបាបដែរ*

អញ្ចឹង តើយើងរាល់គ្នាអាចទីពឹងខ្លួន ហើយត្រឡប់ជាសុចរិតដោយការប្រព្រឹត្តរបស់ខ្លួនបានដែរឬទេ ?

*មិនបានទេ*

៦. តើអ្នកណាអាចសងថ្លៃលោះបាបរបស់យើងបាន ?

*មានតែព្រះយេស៊ូវប៉ុណ្ណោះ*

ហេតុអ្វីបានជាព្រះយេស៊ូវអាចសងថ្លៃលោះបាបទាំងអស់របស់យើងបាន ប៉ុន្តែមនុស្សផ្សេងទៀតមិនអាចសងថ្លៃលោះបាបរបស់យើងបាន ?

*ដោយសារព្រះយេស៊ូវមិនដែលធ្វើបាបណាមួយឡើយ ហើយបានគាប់ព្រះហឫទ័យព្រះវរបិតាក្នុងគ្រប់កិច្ចការទាំងអស់ ទើបទ្រង់អាចសងថ្លៃលោះបាបទាំងអស់របស់យើងបាន ។ មនុស្សផ្សេងទៀត (ដូចជាអ្នកដឹកនាំសាសនាលោកិយជាដើម) មិនអាចសងថ្លៃលោះបាបរបស់យើងបានទេ ព្រោះអ្នកទាំងអស់នោះជាអ្នកមានបាបដូចយើងដែរ ។*

៧. តើសេចក្ដីសន្យាទី២ ដែលព្រះយេស៊ូវបានសន្យាចំពោះអ្នកជឿលើទ្រង់គឺជាអ្វី ?

*ព្រះយេស៊ូវនឹងប្រទានមរតកឲ្យយើង*

៨. មរតកនៃព្រះយេស៊ូវមានពីរផ្នែក តើមានអ្វីខ្លះ ?

*ក. របស់បញ្ចាំចិត្តនៃមរតក ដែលយើងនឹងទទួលបានខណៈពេលដែលយើងកំពុងរស់នៅ*

*ខ. មរតកពេញលេញ ដែលយើងនឹងទទួលក្រោយពេលយើងស្លាប់*

៩. តើរបស់បញ្ចាំចិត្តនៃមរតករបស់យើងគឺជាអ្វី ?

*ព្រះវិញ្ញាណបរិសុទ្ធនៃព្រះនឹងយាងមកសណ្ឋិតនៅជាមួយយើង*

១០. តើព្រះវិញ្ញាណបរិសុទ្ធនៃព្រះមកគង់នៅជាមួយអ្នកជឿនៅពេលណា ?

*ព្រះវិញ្ញាណនៃព្រះនឹងយាងមកគង់នៅជាមួយពួកអ្នកជឿលើទ្រង់ គឺក្នុងខណៈពេលដែលយើងចាប់ផ្ដើមកែប្រែចិត្តពិត និងបានជឿទុកចិត្តលើព្រះយេស៊ូវ*

១១. យោងតាមមេរៀននេះ តើការគង់នៅនៃព្រះវិញ្ញាណបរិសុទ្ធនោះ មានផលប្រយោជន៍អ្វីខ្លះចំពោះយើងនៅពេលឥឡូវនេះ ? (តម្រុយ ៖ មាន២យ៉ាង)

*ក. ព្រះវិញ្ញាណបរិសុទ្ធប្រទានឲ្យយើងនូវជីវិតអស់កល្បជានិច្ចនៅពេលឥឡូវនេះ*

*ខ. ព្រះវិញ្ញាណបរិសុទ្ធបំផ្លាស់បំប្រែចិត្ត ហើយនិងការប្រព្រឹត្តិរបស់យើងនៅពេលឥឡូវនេះ*

១២. តើជីវិតដ៏នៅអស់កល្បជានិច្ចមានន័យថា រូបកាយរបស់យើងមិនចេះស្លាប់មែនឬទេ ?

*មិនមែនទេ*

១៣. តើអ្នកជឿលើព្រះយេស៊ូវគួរខ្លាចសេចក្ដីស្លាប់ដែរឬទេ ?

*មិនគួរខ្លាចសេចក្ដីស្លាប់ឡើយ*

ហេតុអ្វី ?

*ពីព្រោះសេចក្ដីស្លាប់គឺជាការត្រឡប់ទៅឯព្រះនៅឋានសួគ៌*

១៤. តើមនុស្សលោកតែងតែធ្វើអ្វីដែលបង្ហាញថា ពួកគេមានការភ័យខ្លាចចំពោះសេចក្ដីស្លាប់ ?

*មនុស្សជាច្រើនបានចំណាយប្រាក់កាសច្រើន ដើម្បីព្យាយាមការពារខ្លួនពីគ្រោះថ្នាក់ និងពីជំងឺពោគាផ្សេងៗ ដោយការទិញខ្សែចង្កេះ ខ្សែសីមា ព្រលែងសត្វ ឬសាក់យ័ន្តជាដើម*

១៥. តើអ្នកជឿលើព្រះយេស៊ូវគួរខ្លាចវិញ្ញាណអាក្រក់ ព្រាយខ្មោច ឬអារក្សអ្នកតាដែរឬទេ ?

*មិនគួរខ្លាចវិញ្ញាណអាក្រក់ ព្រាយខ្មោច ឬអារក្សអ្នកតាឡើយ*

ហេតុអ្វី ?

*ពីព្រោះព្រះវិញ្ញាណនៃព្រះដែលមានអំណាចលើសលប់នោះ រស់នៅក្នុងខ្លួនអ្នកជឿទាំងនោះ*

១៦. តើសាសនារបស់លោកិយមានអំណាចជួយផ្លាស់ប្ដូរចិត្តរបស់មនុស្សយើងដែរឬទេ ?

*សាសនារបស់លោកិយទាំងអស់គ្មានអំណាចជួយផ្លាស់ប្ដូរចិត្តរបស់មនុស្សយើងបានឡើយ*

១៧. ហេតុអ្វីបានជាអ្នកទាំងអស់ ដែលបានជឿលើព្រះយេស៊ូវពិតប្រាកដនឹងពិតជាមានការផ្លាស់ប្ដូរក្នុងជីវិតរបស់គេ ?

*ពីព្រោះព្រះវិញ្ញាណនៃព្រះដែលគង់នៅជាមួយពួកគាត់ ទ្រង់នឹងជួយអ្នកនោះឲ្យផ្លាស់ប្ដូរបន្តិចម្ដងៗ ដោយព្រះគុណរបស់ព្រះអង្គ*

១៨. តើវិហារនៃព្រះវិញ្ញាណបរិសុទ្ធគង់នៅទីណា ?

*រូបកាយរបស់អ្នកជឿលើព្រះយេស៊ូវ*

១៩. តើមរតកពេញលេញរបស់យើងគឺជាអ្វីខ្លះ ?

*ក. ការរស់នៅជាមួយនឹងព្រះជាម្ចាស់ជារៀងរហូត*

*ខ. ការរស់នៅកន្លែងដែលគ្មានការឈឺចាប់ គ្មានការរងទុក្ខវេទនា គ្មានអំពើបាប ឬសេចក្ដីស្លាប់ឡើយ*

*គ. ការទទួលទ្រព្យសម្បត្តិយ៉ាងបរិបូរពីព្រះវរបិតារបស់យើង*

២០. តើការសន្យាទាំងពីរដែលព្រះបានសន្យាប្រទានឲ្យអ្នកជឿ (ការរួចពីបាប និងការទទួលមរតកនៃព្រះ) មានតម្លៃខ្ពស់ជាងអ្វីខ្លះនៅលើផែនដីនេះ ?

*ការសន្យានៃព្រះទាំងពីរនេះមានតម្លៃខ្ពស់ជាងលុយកាក់ អំណាច កិត្តិយស ឬការសប្បាយ ។ល។*

## សំណួរមេរៀនទី៣ ៖

១. យោងតាមកិច្ចការ ២៦:១៩-២០ នៅពេលលោកប៉ុលបានប្រកាសដំណឹងល្អ តើគាត់បានប្រាប់ប្រជាជនឲ្យធ្វើអ្វី ? (តម្រុយ ៖ មានសកម្មភាព៣យ៉ាង)

*ក. គាត់បានប្រាប់មនុស្សទាំងអស់ឲ្យប្រែចិត្ត (ពីជំនឿចាស់ និងពីអំពើបាបចាស់របស់ពួកគេ)*

*ខ. គាត់បានប្រាប់មនុស្សទាំងអស់ឲ្យងាកបែរមកឯព្រះវិញ*

*គ. គាត់បានប្រាប់មនុស្សទាំងអស់ឲ្យប្រព្រឹត្តបែបសំណំនឹងការប្រែចិត្ត (អ្នកនោះត្រូវតែមានផលផ្លែនៃការប្រែចិត្ត)*

២. ហេតុអ្វីបានជាអ្នកទាំងអស់ដែលបានកែប្រែចិត្តពិតប្រាកដនោះ នឹងមានការផ្លាស់ប្តូរក្នុងជីវិត ?

*ពីព្រោះពួកគេបានងាកចេញពីផ្លូវចាស់របស់ពួកគេ ដើម្បីទៅរកផ្លូវរបស់ព្រះ ហើយឥឡូវនេះ ព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយពួកគេ ហើយកំពុងតែធ្វើការផ្លាស់ប្តូរពួកគេឲ្យដូចជាព្រះយេស៊ូវវិញ*

៣. តើអ្វីខ្លះជាភស្តុតាងដែលបង្ហាញថា ពួកអ្នកជឿនៅក្នុងទីក្រុងអេភេសូរពិតជាបានកែប្រែចិត្តចេញពីជំនឿចាស់ និងអំពើបាបចាស់របស់ពួកគេ ?

*អ្នកជឿលើព្រះយេស៊ូវថ្មីៗនៅក្រុងអេភេសូរបានបំផ្លាញក្បួនតម្រា និងលះបង់វត្ថុសាសនាទាំងអស់របស់ពួកគេដោយដុតចោល ទោះបីជាវាមានតម្លៃស្មើនឹងលុយជាច្រើនក៏ដោយ*

៤. តើអ្វីខ្លះជាភស្តុតាងដែលបង្ហាញថា ពួកអ្នកជឿនៅក្នុងទីក្រុងថែស្សាឡូនីចពិតជាបានកែប្រែចិត្តចេញពីជំនឿចាស់ និងអំពើបាបចាស់របស់ពួកគេ ?

*នៅក្នុងខ៨បានចែងថា ព្រះបន្ទូល និងសេចក្តីជំនឿរបស់អ្នកជឿនៅទីក្រុងថែស្សាឡូនីច «បានផ្សាយចេញពី» ពួកគេបានជា «មិនចាំបាច់ឲ្យយើងខ្ញុំនិយាយអ្វីទៀតទេ» ។ មនុស្សគ្រប់គ្នាបានឃើញការផ្លាស់ប្តូរក្នុងជីវិតរបស់ពួកគេ*

៥. តើមនុស្សយើងអាចគោរព និងបម្រើចៅហ្វាយពីរក្នុងពេលតែមួយបានឬទេ ?

*មិនបានទេ*

៦. យោងតាមមេរៀនរបស់យើង តើពាក្យ «រូបព្រះ» អាចសំដៅទៅលើអ្វីខ្លះ ?

*«រូបព្រះ» គឺជាអ្វីៗទាំងអស់ ទាំងរូបចម្លាក់ ទាំងវត្ថុស័ក្តិសិទ្ធិផ្សេងៗ ដែលយើងចាត់ទុកសំខាន់ជាងព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើង ។ សាវកប៉ុលបានបង្រៀនតាមរយៈព្រះវិញ្ញាណបរិសុទ្ធថា សេចក្តីលោភលន់ចាត់ទុកដូចជាការថ្វាយបង្គំរូបព្រះដែរ*

៧. យោងតាមកាឡាទី ៥:១៩-២១ អ្នកទាំងឡាយណាដែលនៅតែមានចិត្តបន្តប្រព្រឹត្តកិច្ចការខាងសាច់ឈាមនៅឡើយ (ផ្លូវចាស់របស់ពួកគេ) តើពួកគេបានកែប្រែចិត្តពិតប្រាកដដែរឬទេ ?

*អ្នកដែលនៅតែមានចិត្តបន្តប្រព្រឹត្តកិច្ចការខាងសាច់ឈាម អ្នកនោះមិនទាន់កែប្រែចិត្តពិតប្រាកដនោះទេ*

៨. យោងតាមកាឡាទី ៥:២២-២៥ តើបទគម្ពីរនេះបានពិពណ៌នាប្រាប់យើងយ៉ាងដូចម្ដេចខ្លះ ចំពោះការប្រព្រឹត្តិរបស់អ្នកដែលបានកែប្រែចិត្តរួចហើយ ?

*អ្នកដែលបានកែប្រែចិត្តរួចហើយ នឹងលែងប្រព្រឹត្តកិច្ចការខាងសាច់ឈាម ហើយគាត់នឹងបង្កើតផលផ្លែនៃព្រះវិញ្ញាណបរិសុទ្ធវិញ*

## សំណួរមេរៀនទី៤ ៖

១. នៅពេលដែលសាវកប៉ុលបានអធិប្បាយ ហើយបង្រៀនដល់សាសន៍យូដាជាច្រើន តើគាត់ទទួលបានការឆ្លើយតបបែបណាពីពួកគេ ?

*មនុស្សខ្លះបានស្អប់លោកប៉ុល ហើយបានព្យាយាមសម្លាប់គាត់ចោល*

២. ហេតុអ្វីបានជាពួកគេស្អប់សាវកប៉ុលខ្លាំងម្លេះ ?

*ពីព្រោះពួកគេស្អប់ការអធិប្បាយរបស់គាត់ ជាពិសេសការបង្រៀនអំពីភាពចាំបាច់នៃការកែប្រែចិត្ត*

៣. តើអ្នកជឿលើព្រះយេស៊ូវទាំងអស់ប្រឈមមុខនឹងការបៀតបៀនដែរឬទេ ?

*អ្នកជឿលើព្រះយេស៊ូវទាំងអស់ប្រឈមមុខនឹងការបៀតបៀន*

៤. យោងតាមលូកា ១៤:២៥-២៧ តើព្រះយេស៊ូវបានបង្រៀនយើងអំពីអ្វីខ្លះ ដែលយើងត្រូវតែព្រមធ្វើ ដើម្បីធ្វើជាសិស្សដ៏ពិតរបស់ព្រះយេស៊ូវ ? (តម្រុយ ៖ មាន២យ៉ាង)

*ក. យើងត្រូវព្រមលះអាល័យពីមនុស្ស និងរបស់ទ្រព្យខ្លួនទាំងអស់*

*ខ. យើងត្រូវព្រមផ្ទុកឈើឆ្កាងខ្លួន*

៥. តើការលះអាល័យពីឪពុកម្ដាយ បងប្អូនប្រុសស្រី ប្ដីប្រពន្ធ និងកូនចៅ ដើម្បីដើរតាមព្រះយេស៊ូវ មានអត្ថន័យយ៉ាងដូចម្ដេចខ្លះ ?

*ពាក្យ «លះអាល័យ» ក្នុងខគម្ពីរនេះមិនមែនមានន័យថា ព្រះយេស៊ូវសព្វព្រះហឫទ័យឲ្យយើងឈប់ស្រឡាញ់ក្រុមគ្រួសាររបស់យើង ឬប្រឆាំងនឹងពួកគេនោះទេ! ព្រះយេស៊ូវមានបន្ទូលបំផ្លើស ដើម្បីឲ្យយើងចាប់អារម្មណ៍ថា ត្រូវស្រឡាញ់ព្រះជាម្ចាស់ខ្លាំងបំផុត ។ បើប្រៀបផ្ទឹមការស្រឡាញ់របស់យើងចំពោះគ្រួសារ វត្ថុផ្សេងៗ និងជីវិតរបស់ខ្លួនឯង ទៅនឹងការស្រឡាញ់របស់យើងចំពោះព្រះជាម្ចាស់ ហាក់ដូចជាយើងបានលះបង់គ្រួសាររបស់យើងទៅវិញ!*

៦. តើការផ្ទុកឈើឆ្កាងរបស់យើងមានអត្ថន័យយ៉ាងដូចម្ដេចខ្លះ ?

*ក. ការសុខចិត្តបាត់បង់មនុស្ស និងរបស់ទ្រព្យខ្លួន*

*ខ. ការសុខចិត្តទទួលការរងទុក្ខ*

៧. តើឧទាហរណ៍ទាំងពីរ ដែលព្រះយេស៊ូវបានលើកឡើងបន្ទាប់ពីសេចក្ដីបង្រៀនរបស់ទ្រង់នៅក្នុងលូកា ១៤:២៥-២៧ មានអ្វីខ្លះ ?

*ក. អ្នកសង់ផ្ទះពីថ្ម*

*ខ. ស្ដេចទៅច្បាំងនឹងស្ដេចមួយទៀត*

៨. ហេតុអ្វីបានជាព្រះយេស៊ូវលើកយកឧទាហរណ៍ទាំងពីរមកប្រើបន្ទាប់ពីសេចក្ដីបង្រៀនរបស់ទ្រង់ ?

*ពីព្រោះព្រះយេស៊ូវចង់ឲ្យយើងគិតពិចារណាមុនអំពីការលះបង់ ដើម្បីធ្វើជាសិស្សរបស់ទ្រង់ ដូចជាអ្នកសង់ផ្ទះពីថ្ម និងស្ដេចដែលទៅច្បាំងនឹងស្ដេចមួយទៀតក៏បានគិតពិចារណាមុនយ៉ាងនោះដែរ*

៩. យោងតាម១ពេត្រុស ៤:១-៤ តើអ្វីជាមូលហេតុដែលអ្នកមិនជឿចំអកចំអន់ឲ្យអ្នកជឿលើព្រះយេស៊ូវ ?

*ពីព្រោះតែអ្នកជឿមិនព្រមធ្វើតាមទង្វើនៃអំពើបាបរបស់ពួកគេ*

១០. យោងតាមម៉ាថាយ ៥:១០-១២ និងលូកា ៦:២២-២៣ តើអ្នកជឿលើព្រះយេស៊ូវគួរតែមានឥរិយាបថបែបណាចំពោះការបៀតបៀន ?

*អ្នកជឿលើព្រះយេស៊ូវគួរតែមានចិត្តអំណរ និងរីករាយជាខ្លាំងនៅក្នុងការរងទុក្ខរបស់ពួកគេ*

១១. តើព្រះយេស៊ូវបានសន្យាប្រទានអ្វីខ្លះចំពោះអ្នកដែលបានទទួលនូវសេចក្តីបៀតបៀនដោយព្រោះព្រះនាមព្រះអង្គ ?

*គាត់នឹងទទួលព្រះពរ និងរង្វាន់ជាធំនៅឋានសួគ៌*

១២. យោងតាម១ពេត្រុស ៤:១២-១៦,១៩ តើអ្នកជឿលើព្រះយេស៊ូវត្រូវធ្វើអ្វីខ្លះ នៅពេលដែលមានអ្នកមិនជឿមកបៀតបៀន ?

*អ្នកជឿលើព្រះយេស៊ូវត្រូវតែទុកចិត្តលើសេចក្តីស្មោះត្រង់របស់ព្រះ ហើយជឿជាក់លើការសន្យារបស់ទ្រង់ថា ទ្រង់នឹងផ្តល់សេចក្តីយុត្តិធម៌នៅថ្ងៃជំនុំជម្រះ*

## សំណួរមេរៀនទី៥ ៖

១. តើនរណាបានបង្គាប់ឲ្យអ្នកជឿទាំងអស់ទទួលពិធីជ្រមុជទឹក ?

*ព្រះយេស៊ូវ*

២. យោងតាមមេរៀនរបស់យើង តើអ្វីដែលមិនមែនជាអត្ថន័យពិតនៃពិធីជ្រមុជទឹក ? (តម្រុយ ៖ មាន៣យ៉ាង)

*ក. ពិធីជ្រមុជទឹកមិនមែនជាពិធីសាសនាមួយដែលយើងត្រូវធ្វើ ដើម្បីទទួលបានសំណាងល្អសម្រាប់ក្រុមគ្រួសារ ឬមុខជំនួញរបស់យើងនោះទេ*

*ខ. ពិធីជ្រមុជទឹកមិនមែនជាវិធីមួយ ដើម្បីសម្អាតអំពើបាបរបស់យើងនោះទេ*

*គ. ពិធីជ្រមុជទឹកមិនមែនជាផ្នែកសំខាន់អ្វីមួយនៃសេចក្តីសង្គ្រោះដែលនាំឲ្យយើងរួចពីអំពើបាបនោះទេ*

៣. យោងតាមមេរៀនរបស់យើង តើអត្ថន័យនៃពិធីជ្រមុជទឹកមានអ្វីខ្លះ ? (តម្រុយ ៖ មាន៣យ៉ាង)

*ក. ពិធីជ្រមុជទឹកជាទីបន្ទាល់នៃសេចក្តីសង្គ្រោះរបស់យើងក្នុងព្រះគ្រីស្ទ*

*ខ. ពិធីជ្រមុជទឹកជាទីសម្គាល់នៃអ្វីៗដែលបានកើតឡើងចំពោះយើងខាងវិញ្ញាណ*

*គ. ពិធីជ្រមុជទឹកជាការសម្រេចចិត្តចូលជាសមាជិកនៅក្នុងក្រុមជំនុំតាមតំបន់មួយ*

៤. យោងតាមមេរៀនរបស់យើង តើពិធីជ្រមុជទឹកមានទីសម្គាល់អ្វីខ្លះ ? (តម្រុយ ៖ មាន៣យ៉ាង)

*ក. ពេលយើងឈរនៅក្នុងទឹក នោះជានិមិត្តរូបពីការរស់ក្នុងជីវិតចាស់ និងផ្លូវចាស់របស់យើង*

*ខ. ពេលយើងជ្រមុជនៅក្នុងទឹក នោះជានិមិត្តរូបពីការស្លាប់ខាងជីវិតចាស់ និងផ្លូវចាស់របស់យើង*

*គ. ពេលយើងងើបពីទឹកវិញ នោះជានិមិត្តរូបពីការរស់ឡើងវិញជាមួយព្រះយេស៊ូវ ដោយព្រះបានប្រទានឲ្យយើងបានជីវិតថ្មីក្នុងព្រះយេស៊ូវគ្រីស្ទ*

៥. តើយើងក្លាយទៅជាអ្វី នៅពេលដែលយើងបានទទួលពិធីជ្រមុជទឹករួច ?

*យើងក្លាយទៅជាសមាជិកនៅក្នុងក្រុមជំនុំតាមតំបន់មួយ*